ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jul-2013, 14:05
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៨នាទី**

**សវនាការលើកទី២១៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ស្ទីវ ហេដឌ័រ (TCE-33) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស្ទីវ ហេដឌ័រ** (TCE-33)
សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ..........................................................ទំព័រ ៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៨:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅព្រឹកនេះអង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ស៊ីវ ហេងឆ័រ បន្ត ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការព្រឹកនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នេះរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនដែលនៅពីខាងក្រោមបន្ទប់សវនាការនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ ចំណែកឯសាក្សីលោកស៊ីវ ហេងឆ័រ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី សែ កុលវុឌ្ឍី។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

សូមផ្អាកបន្តិចសិនលោកស្រីមេធាវី!

លោកស៊ីវ ហេងឆ័រ លោកមានបញ្ហាអី?

[០៩:០៩:៣៤]

**លោក ស៊ីវ ហេងឆ័រ៖**

ប្រសិនបើអនុញ្ញាតនោះ គឺថាខ្ញុំសូមលើកឡើងអំពីបញ្ហាពាក្យដែលបកប្រែនោះ។ សូមឲ្យលោក

ចៅក្រមអនុញ្ញាត គឺខ្ញុំលើកតែបីពាក្យទេ ដើម្បីកុំឲ្យមានការភ័ន្តភាំងច្រឡំគ្នា។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក ស្ទីវ!

**លោក ស្ទីវ ហេដឌ័រ៖**

សូមអរគុណ។ លេខកូដ និងអក្សរកាត់។ ដូចគេប្រាប់ខ្ញុំក្នុងពេលសម្ភាសជាច្រើនពាក្យទាំងអស់ហ្នឹង ភាសាទាំងអស់ហ្នឹងគឺគេប្រើប្រាស់ដើម្បីឲ្យយើងយល់ ឬក៏ទុកឲ្យមានការយល់ច្រឡំតែម្តង គឺគេមិនប្រើច្បាស់នោះទេ ទើបគេប្រើពាក្យដូច្នោះ។

ចំណុចទី២ ពាក់ព័ន្ធទៅនឹងភាសា អ្នកសិក្សាស្រាវជ្រាវ និងអ្នកឆ្លាតវ័យនោះ គឺគេបានធ្វើការបកស្រាយទៅលើពាក្យហ្នឹង។ ហើយគេយល់ថាពាក្យហ្នឹងប្រើប្រាស់នៅទូទាំងសហគមន៍របស់របស់ពួកជនកុម្មុយនីស្ត។

ខ្ញុំបានធ្វើអនុវត្តតាមអ្នកដែលសិក្សាស្រាវជ្រាវ ឬក៏អ្នកដែលគាត់ជាអ្នកបង្កើតពាក្យទាំងអស់ហ្នឹង។ អ្វីដែលមានន័យក្នុងហ្នឹងគឺថា ខ្ញុំគ្រាន់តែបង្ហាញចំណុចដែលខុសនៅក្នុងការបកប្រែតែប៉ុណ្ណោះ ដោយសារតែពេលដែលបកខុសនោះ វាអាចដោយសារតែការខ្វះសមត្ថភាពទៅលើការបកប្រែពាក្យនោះតែប៉ុណ្ណោះ មិនមែនថាគេប្រើនោះខុសនោះទេ។ ការដែលគេប្រើពាក្យទាំងអស់នោះ គឺជាការបង្កើតឡើងដោយក្រុមគេ ហើយការបកប្រែនោះគឺវាជាកំហុសខាងបកប្រែទេ មិនមែនជាកំហុសរបស់អ្នកដែលគេបង្កើតពាក្យទាំងអស់នោះយកមកប្រើប្រាស់ ឬក៏អ្នកសិក្សាស្រាវជ្រាវដែលបានប្រើពាក្យទាំងអស់នោះឡើយ។

[០៩:១១:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគី ជម្រាបសួរលោក ហេដឌ័រ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមអរគុណដែលលោកបានបំភ្លឺអំពីពាក្យអម្បាញ់មិញនេះ។ ហើយឥឡូវនេះ ខ្ញុំនឹងលើក

ឡើងនូវពាក្យពេចន៍មួយចំនួន ហើយនិងការបកប្រែមួយចំនួនពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ។

ខ្ញុំចង់មានចំណុចមួយសូមឲ្យលោកបំភ្លឺ តើពាក្យថា *"កុំមីតេ សង់ត្រាល់"*– គណៈមជ្ឈិមហ្នឹង លោកបកប្រែថាម៉េចដែរ ជាភាសាខ្មែរ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ពាក្យពេញរបស់វាគឺថា គណៈកម្មាធិការមជ្ឈិម។

[០៩:១២:៤១]

**ស៖** ហើយចុះខ្លី ភាសាខ្លី ប្រើកាត់ យើងប្រើថាម៉េចដែរ?

**ឆ៖** អាចគេប្រើថា"គណៈមជ្ឈិម"។ គឺគេប្រើពាក្យថា"*សេនត្រល ខម*" – គណៈមជ្ឈិម។ ប៉ុន្តែនៅពេលដែលគេប្រើសរសេរដូច្នោះ វាទុកឲ្យមានភាពស្រពេចស្រពិល។ វាអាចសំដៅទៅលើប្រធានរបស់គណៈកម្មាធិការមជ្ឈិម ឬក៏គេសរសេរពាក្យកាត់ហ្នឹង គេសំដៅលើបុគ្គលម្នាក់នៅក្នុងគណៈកម្មាធិការហ្នឹង។ ការដែលគេប្រើប្រាស់ដូច្នេះ គេប្រើប្រាស់នៅទូទាំងរចនាសម្ព័ន្ធតែម្តង ដូចជាពាក្យថា "គណៈតំបន់" វាអាចសំដៅទៅលើថា "គណៈកម្មាធិការតំបន់" ឬក៏សំដៅទៅលើលេខារបស់គណៈកម្មាធិការតំបន់ ឬក៏វាសំដៅទៅលើសមាជិករបស់គណៈកម្មាធិការតំបន់។ នៅពេលដែលយើងមើលបរិបទវាទើបយើងអាចយល់ប្រាកដ ថាតើគេសរសេរនុំងសំដៅលើអ្វីឲ្យបានជាក់លាក់។

**ស៖** ខ្ញុំសូមបន្តទៅទៀតលោក ហេងឆ័រ។ កាលពីថ្ងៃទី១៥ ខែកក្កដា សហព្រះរាជអាជ្ញាបានលើកឡើងនូវអត្ថបទរបស់លោកគឺ បេក្ខជនប្រាំពីរនាក់សម្រាប់ការកាត់ទោស គឺលេខ E3/48 គឺថានៅម៉ោង១០:២៩នាទី។ ហើយជាពិសេសហ្នឹងគឺទំព័រ៦៤ ជាភាសាអង់គ្លេស។ អង់គ្លេសគឺ 00393553, ជាភាសាបារាំង 00729654, ជាភាសាខ្មែរ 00742609។ លោកបានលើកឡើងអំពីរបាយការណ៍ -- លោកនិយាយថារបាយការណ៍ទាំងអស់នុំងគឺជូនការផ្ញើជូនជាពិសេសចំពោះ ប៉ុល ពត ដោយរួមមានអក្សរកាត់ ឬឈ្មោះហៅក្រៅថា "០០៩" តែញឹកញ័យជាងនេះ គេគ្រាន់តែសរសេរថា "ផ្ញើជូនបង ឬក៏អង្គការ" ឬបើផ្ញើទៅគណៈមជ្ឈិមគេប្រើលេខកូដរបស់វាគឺ"៨៧០"។ សូមបញ្ចប់ការដកស្រង់។

[០៩:១៥:២៧]

សំណួររបស់ខ្ញុំគឺខ្ញុំចង់ដឹងអំពីកាលបរិច្ឆេទនៃការសរសេររបាយការណ៍នេះ តើលោកបានប្រភពឯកសារមកពីណាដើម្បីសរសេរបែបនេះ? ដើម្បីបញ្ជាក់ថា គេផ្ញើទៅឲ្យ ប៉ុល ពល ហ្នឹង ដោយហៅឈ្មោះថា ហៅឈ្មោះកូដថា "០០៩"? ហើយបន្ទាប់មកទៀតនៅក្នុងក្របខ័ណ្ឌនៃការងាររបស់លោកក្នុង

ការិយាល័យសហព្រះរាជអាជ្ញា ឬក៏ការិយាល័យសហចៅក្រមស៊ើបអង្កេត តើលោកមានឯកសារណាផ្សេងទៀត ដើម្បីឲ្យមានភាពស៊ីសង្វាក់ក្នុងការដែលគេហៅ ប៉ុល ពត ថាលេខកូដ “០០៩” នេះ?

**ឆ៖** ឆ្លើយទៅនឹងសំណួរទី១ តាមខ្ញុំចាំមិនខុស ការស្រាវជ្រាវជាមូលដ្ឋាន គឺបានបង្ហាញដូចតទៅ គឺបានបង្កើតជារបាយការណ៍មួយដែលបានបោះពុម្ពផ្សាយ នៅក្នុងឆ្នាំ -- ចុងឆ្នាំ១៩៨០ ប្រហែលជា៨៨ ឬក៏៨៩ ឬក៏ប្រហែល៨៩ និងឆ្នាំ៩០ ប្រហែលជាផលិតក្នុងឆ្នាំហ្នឹង។ មូលដ្ឋានឯកសារដែលគេយកសំអាង រួមទាំងសម្ភារៈឯកសារដែលខ្ញុំមាន ទទួលមកតាមរយៈលោក ដេវីដ ឆេនដ៍ល័រ ហើយនិងសម្ភារៈឯកសារដែលគេផ្ដល់ឲ្យខ្ញុំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារមួយចំនួន ប៉ុន្តែមិនមែនទាំងអស់នោះទេ គឺសារទូរលេខ និងរបាយការណ៍ដែលមានលក្ខណៈស៊ីសង្វាក់គ្នា ដូចគ្នាហ្នឹង។

[០៩:១៧:១៤]

ក្រោយមក គឺថាតុលាការនេះ ក៏មានឯកសារទាំងអស់នោះដែរ។ ខ្ញុំមិនចាំជាក់លាក់ថាបានឃើញព័ត៌មានដែលគេបញ្ជាក់ថា គេប្រើលេខកូដ០០៩នោះឡើយ នៅពេលដែលខ្ញុំធ្វើការងារនៅក្នុងតុលាការនេះ។ កាលពីមុនក៏ខ្ញុំមិនដែលឃើញដែរ។ តាមខ្ញុំចាំ គឺវាចម្លែកចំពោះការប្រើប្រាស់លេខដូច្នេះ។ ខ្ញុំសូមលើកឡើងផងដែរថា នៅក្នុងអត្ថបទហ្នឹង ខ្ញុំនិយាយថាគណៈកម្មាធិការមជ្ឈិមនោះ គឺលេខ៨៧០ នោះគឺខ្ញុំនៅតែប្រើប្រាស់ពាក្យនេះដដែល តាមពាក្យរបស់វា។ ដូចដែលខ្ញុំបញ្ជាក់នៅក្នុងសក្ខីកម្មរបស់ខ្ញុំកាលពីមុនអ៊ីចឹង វាជាការយល់ថា ៨៧០នេះ សំដៅទៅលើកម្រិត ឬក៏រចនាសម្ព័ន្ធនៅក្នុងហ្នឹង ឬក៏អ្នកដែលស្ថិតនៅក្នុងកម្រិតហ្នឹង។ ធ្វើការប្រៀបធៀបនៅពេលដែលអាមេរិក អ្នកនយោបាយអាមេរិកនិយាយថា “វ៉ាស៊ីនតោន” អ៊ីចឹងគឺបានន័យថា សំដៅទៅលើបុគ្គលដែលនៅក្នុងថ្នាក់លើៗនៅក្នុងហ្នឹង។ អ៊ីចឹងគេប្រើលេខកូដគ្នាអ៊ីចឹង។ តើនរណាគេនៅក្នុងវ៉ាស៊ីនតោន? អ្វីទៅជាវ៉ាស៊ីនតោន? គឺគេមិនបញ្ជាក់ឲ្យច្បាស់នោះទេ។ គេទុកឲ្យយើងយល់តាមខ្លួនឯង។

[០៩:១៨:៣៨]

**ស៖** ពាក់ព័ន្ធទៅនឹងចំណុចនេះដែរ ខ្ញុំចង់ដឹងថា កាលពីម្សិលមិញនោះលោកបានឆ្លើយថា ក្នុងក្របខ័ណ្ឌនៃការងាររបស់លោកនៅ អ.វ.ត.ក លោកទទួលបានឯកសារទាំងអស់នៅក្នុងសំណុំរឿង។ ដូច្នេះ តើលោកអាចពិនិត្យមើលចម្លើយរបស់លោក ខៀវ សំផន ដែលបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ គឺបាន។

**ស៖** ពាក់ព័ន្ធទៅនឹងចំណុចជាក់លាក់នៃពាក្យលេខកូដ "៨៧០"។ នៅក្នុងឯកសារ E3/37, ERN ជាភាសាបារាំង 00156681, ជាភាសាខ្មែរ 00156676, ជាភាសាអង់គ្លេសគឺ 00156754។ គាត់និយាយអំពីគណៈ៨៧០។

ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បញ្ចាំងទំព័រនេះនៅលើអេក្រង់។ "គណៈ៨៧០ និង អង្គការ៨៧០ គឺជាបក្ស គឺ ប៉ុល ពត, គាត់ចុះហត្ថលេខា៨៧០ ឬក៏៨៧។ ចំពោះក្រុមការងារ៨៧០ គឺជាផ្នែកមួយនៃមន្ទីរ៨៧០"។ សូមអរគុណ សូមបញ្ចប់ការដកស្រង់។

សំណួរទី១ពាក់ព័ន្ធនឹងចំណុចនេះ តើនៅក្នុងក្របខ័ណ្ឌនៃការអង្កេតរបស់លោកនៅមុនក្នុងអំឡុងពេលនិងក្រោយពេលដែលលោកបំពេញការងារជាមួយនឹងតុលាការ គឺនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា តើលោកធ្លាប់ឃើញឯកសារដែលមានហត្ថលេខា៨៧០ ឬក៏៨៧ ដែលជាហត្ថលេខានៅលើឯកសារដែលចេញពី ប៉ុល ពត ផ្ទាល់? តើលោកធ្លាប់ដឹងព័ត៌មាននេះទេ ឬក៏ធ្លាប់ទទួលព័ត៌មាននេះ ទទួលបានឯកសារបែបនេះពីប្រភពណាផ្សេងទៀត ដែលបានមកពីការសម្ភាសនោះ?

[០៩:២១:៤២]

**ឆ៖** តាមខ្ញុំចាំគ្មានក្រដាស ឬក៏ឯកសារណាមួយដែលខ្ញុំបានឃើញក្រោយពីខ្ញុំបានចូលរួមធ្វើការជាមួយនឹងតុលាការនេះ ឬក៏គ្មានប្រភពណាមួយផ្សេងដែលបញ្ជាក់ឲ្យបានច្បាស់លាស់ថា ការប្រើប្រាស់អក្សរកាត់ លេខកូដនុ៎ង ជាពិសេសគេប្រើប្រាស់ក្នុងន័យហ្នឹង សំដៅលើ ប៉ុល ពត នោះទេ។ តាមខ្ញុំចាំ ៨៧០ គឺគេប្រើក្រោយ មករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។ គេប្រើញឹកញាប់ក្រោយពេលនុ៎ង។ ដូចដែលខ្ញុំទើបតែបាននិយាយលើកឡើងអ៊ីចឹង នៅ -- វាអាស្រ័យទៅលើបរិបទនានា ឃ្លាដែលថា គណៈ៨៧០ ឬក៏អង្គការ៨៧០នេះ ឬក៏គេប្រើស្រដៀងៗគ្នានៅក្នុងថ្នាក់ក្រោមបក្ស ឬក៏នៅក្នុងបក្ស ការប្រើប្រាស់ទាំងអស់នេះ គឺមានចេតនាទុកឲ្យមានភាពស្រពេចស្រពិលដូច្នេះ។ គណៈ៨៧០ សំដៅលើគណៈកម្មការទាំងមូល សំដៅលើប្រធាន ឬក៏សំដៅលើលេខា ឬក៏សំដៅទៅលើសមាជិកក្នុងហ្នឹងម្នាក់ណាមួយនៅក្នុងគណៈកម្មាធិការ។

[០៩:២៣:១០]

"អង្គការ" តាមគេប្រាប់ខ្ញុំ គេពន្យល់ប្រាប់ខ្ញុំ "អង្គការ គឺសំដៅអ្នកដែលនៅថ្នាក់លើ" ក៏ប៉ុន្តែថា តើនៅថ្នាក់នោះវាខ្ពស់ប៉ុនណា វាជាបញ្ហាដែលត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់។ ដូច្នេះ អ្វីដែលបានបញ្ជាក់

បានច្បាស់ជូនខ្ញុំ ឬក៏អ្នកដែលព្យាយាមពន្យល់ឲ្យខ្ញុំបានច្បាស់តាមសំណួររបស់ខ្ញុំនោះ គឺយើងត្រូវតែចូលរួមអនុវត្តនៅក្នុងហ្នឹងផ្ទាល់ អ្នកអនុវត្តនៅក្នុងហ្នឹងផ្ទាល់ ក្នុងករណីនីមួយៗទើបគាត់អាចយល់។ ដូចដែលគេបានរៀបរាប់ប្រាប់ខ្ញុំអ៊ីចឹង វាអាស្រ័យទៅលើភាពជាក់ស្ដែង សំដៅ -- ពេលខ្លះវាសំដៅទៅលើលេខភូមិភាគ គណៈកម្មាធិការភូមភាគ ឬក៏សមាជិកគណៈកម្មាធិការភូមិភាគ។ អ៊ីចឹង វាអាស្រ័យទៅលើប្រតិបត្តិការនៅក្នុងតំបន់ ឬក៏កន្លែងគេ។

[០៩:២៤:០៨]

ភាពជាក់ស្ដែងដែលគេរៀបរាប់ប្រាប់ខ្ញុំនោះ គឺថាមានលក្ខណៈខុសៗគ្នា។ ដូច្នេះ ខ្ញុំគិតថាវា-- គេប្រើប្រាស់ពាក្យនៅក្នុងនុ៎ង គឺវាអាចអនុវត្តចំពោះកម្រិតក្របខ័ណ្ឌនុ៎ងមែន។ វាអាចមានន័យដូចដែលគេនិយាយនៅក្នុងឯកសារអម្បាញ់មិញអ៊ីចឹង ក៏ប៉ុន្តែវាអាចមានន័យក្រៅពីហ្នឹងផងដែរ វាអាស្រ័យទៅលើការបកប្រែទៅតាមលក្ខណៈសាមញ្ញរបស់វាតែប៉ុណ្ណោះ។ ខ្ញុំសូមអធ្យាស្រ័យ ខ្ញុំសូមបន្តទៀត។ ការលើកឡើងនៅក្នុងនេះថា ក្រុមការងារ *វើកឃីងធីម* ឬក៏ *វើកឃីងគ្រុប* ក្រុមការងារ៨៧០។ ខ្ញុំមិនមែននិយាយថា ខ្ញុំមិនដែលស្ដាប់ឮគេប្រើពាក្យដូច្នេះនោះទេ មុនពេលដែលខ្ញុំមកចូលរួមធ្វើការងារនៅ យូ.អិន.អេ.ខេ.អ័រ.ធី ដើម្បីជួយការងារតុលាការ។ ហើយក៏មិនមែនថាខ្ញុំមិនដែលធ្លាប់ឮពាក្យហ្នឹងតាំងពីមុនមកនោះដែរ។ តាមខ្ញុំចាំពាក្យហ្នឹង វាលេចចេញមកពីសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ហើយខ្ញុំមិនដែលធ្លាប់ឃើញនៅកន្លែងផ្សេងក្រៅពីហ្នឹងនោះទេ។ ចំពោះមន្ទីរពហុវចនៈ ឬក៏ឯកវចនៈ សំដៅលើថាមន្ទីរ៨៧០នោះ តើពហុវចនៈ ឬឯកវចនៈនោះ វាអាស្រ័យទៅលើបរិបទ ឬក៏គេសំដៅលើអ្វីទើបយើងអាចយល់បាន។

[០៩:២៥:៤៤]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់របស់លោក។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីកិច្ចសម្ភាសន៍កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ៧៦ ជាមួយលោក អៀង សារី។ ប្រតិចារឹកនៃកិច្ចសម្ភាសន៍នេះគឺមាននៅក្នុងឯកសារ E3/99 ហើយកាលពីថ្ងៃទី១៥ កក្កដា កន្លងទៅនេះ លោកបានលើកឡើងអំពីកិច្ចសម្ភាសន៍នេះជាមួយនឹងសហព្រះរាជអាជ្ញា គឺថានៅហ្នឹងប្រហែលជាម៉ោង១៤:៣៨នាទី។ កាលកិច្ចសម្ភាសន៍នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៦ហ្នឹង គឺជាកិច្ចសម្ភាសន៍ដែលវែងដែលលោកបានធ្វើជាមួយលោក អៀង សារី មែនទេ?

**ឆ៖** បាទជាការពិតដូច្នេះមែន។

**សៈ** ខ្ញុំនិយាយពាក់ព័ន្ធទៅនឹងពាក្យពេចន៍ដដែល។ ខ្ញុំចង់ដកស្រង់នូវឃ្លានៃកិច្ចសម្ភាសន៍នេះ ហើយខ្ញុំសូមឲ្យលោកបញ្ជាក់ពាក់ព័ន្ធទៅនឹងចំណុចនេះ។ ឯកសារនេះគឺលេខ E3/89 ជាភាសាបារាំងគឺ 00332700, ជាភាសាខ្មែរគឺ 0062477, ជាភាសាអង់គ្លេស 00417619។ ដូច្នេះ ខ្ញុំសូមប្រគល់ឯកសារប្រតិចារឹកនេះទាំងស្រុកជាភាសាអង់គ្លេស និងជាភាសាខ្មែរជូនលោក ហេដឌ័រ។

**កញ្ញា អង់តា ហ្គីសសេៈ**

ដូច្នេះ សូមការអនុញ្ញាតពីលោកប្រធានដើម្បីឲ្យមន្ត្រីតុលាការយកឯកសារនេះជូនគាត់។ ហើយសូមការអនុញ្ញាតដើម្បីបង្ហាញផ្នែកពាក់ព័ន្ធនេះនៅលើអេក្រង់ផងដែរលោកប្រធាន គឺជាភាសាខ្មែរ។

**ប្រធានអង្គជំនុំៈ**

អង្គជំនុំជម្រះអនុញ្ញាត។

[០៩:២៨:៣២]

**សួរដោយកញ្ញា អង់តា ហ្គីសសេៈ**

**សៈ** ខ្ញុំសូមប្រាប់ ERN ម្តងទៀតគឺជាភាសាអង់គ្លេស -- ជាភាសាខ្មែរមុន គឺលោកអាចពិនិត្យមើលបានគឺ 00062477។ លោកបានសួរសំណួរមួយទៅកាន់លោក អៀង សារី។ ខ្ញុំសូមអានសំណួរ និងចម្លើយទាំងស្រុងដើម្បីឲ្យអាចឆ្លើយឲ្យបានច្បាស់ទៅនឹងសំណួររបស់ខ្ញុំ។ ស្មីវ ខ្ញុំយល់ឃើញថាបញ្ហាហ្នឹង--

**អ្នកបកប្រែៈ**

លោកប្រធាន សូមឲ្យមេធាវីគាត់អានឡើងវិញ អ្នកបកប្រែតាមអត់ទាន់លោកប្រធាន!

[០៩:២៩:៤១]

**សួរដោយកញ្ញា អង់តា ហ្គីសសេៈ**

**សៈ** គឺនៅពាក់កណ្តាលសំណួរដែលចាប់ផ្តើមឡើងដោយថា "ខ្ញុំគិតថាប្រសិនបើខាងឋានានុក្រមនោះ គឺនួន ជា និង ខៀវ សំផន គឺមានន័យថាមួយម៉ាត់ថាខាងចាត់តាំងអប់រំមួយ ហើយខាងរណសិរ្សមួយ។ ដល់អស់ពីរណសិរ្សទៅ គឺនៅសល់តែខាងអប់រំចាត់តាំង។ តើអ៊ីចឹងទេ?" ចម្លើយរបស់លោក អៀង សារី "បញ្ហាហ្នឹងគឺ ខៀវ សំផន កាលហ្នឹងប្រធានមន្ទីរដែរ ក៏ប៉ុន្តែប្រធានមន្ទីរខាងឧស្សាហកម្មខាងអី។ អ៊ីចឹងប្រធានមន្ទីរមានពីរបី។ ប្រធានមន្ទីរហ្នឹងគឺ ប៉ង់ ធ្វើប្រធានសេដ្ឋកិច្ច។ មាន ប៉ង់ ហ្នឹងធំជាងគេហើយ។ ហើយមិត្ត ខៀវ សំផន គេហៅថារណសិរ្ស ក៏ប៉ុន្តែក្នុងហ្នឹង ចូលក្នុងមន្ទីរហ្នឹងដែរ។

គាត់គិតគូរខាងបញ្ញាជន ខាងរណសិរ្ស។ ប្រធានមន្ទីរមានអ្នកណាទៀត? មាន លឹម ហើយមានមួយទៀតគឺ ភុំ។ ភុំ កាន់ខាងសាលា? បាទ គាត់ខាងសាលា។ ខាងសាលារៀន គិតគូរក្នុងសាលារៀន ផ្ញើផ្ទាល់ទៅ នួន ជា ទាំងអស់"។ សំណួររបស់ ស្ទីវ៖ "លឹម ហ្នឹងខាងណាដែរ?" ចម្លើយរបស់លោក អៀង សារី "លម ហ្នឹងខាងសន្តិសុខ។ លឹម ទទួលការពារទេ លឹម មិនមែនសន្តិសុខទេ។ ហ្នឹងហើយគាត់ការពារផង។ (ក្រោយពេលដែល ប៉ង់ ស្លាប់ លឹម ទទួលរួមទាំងអស់)។ ហ្នឹងហើយទទួលរួមទាំងអស់ លឹម ហ្នឹង។ ឥឡូវគាត់ស្លាប់ហើយ"។ សូមបញ្ចប់ការដកស្រង់។

សូមទោសគឺខ្ញុំបន្តទៅទៀត "គឺគាត់ហ្នឹងជាជនជាតិចារ៉ាយ"។ សូមបញ្ចប់ការដកស្រង់។

[០៩:៣១:៥៤]

មូលហេតុដែលខ្ញុំអានឃ្លានេះឲ្យលោកស្តាប់នោះ គឺថានៅក្នុងឃ្លានេះគេនិយាយអំពីមន្ទីរដែលបារាំង គេហៅថា "ប៊ុយរ៉ូ" គឺថាមន្ទីរឧស្សាហកម្ម។ ដូច្នេះ នៅពេលដែលយើងអានឃ្លាហ្នឹងទៅ យើងមិនដឹងថាតើនិយាយពីមន្ទីរអីទេ ដែលថា "មន្ទីរៗ"នៅក្នុងឯកសារនេះ។ អ៊ីចឹងតើលោកអាចបំភ្លឺបានទេថាមន្ទីរហ្នឹង មន្ទីរអីដែរ? ហើយពេលនុ៎ងគឺថានិយាយពីសម័យកាលណាដែរ? ដូច្នេះ លោកអាចពិនិត្យមើលឯកសារ ហើយអាចឆ្លើយបញ្ជាក់ឲ្យខ្ញុំឲ្យបានច្បាស់។ គឺថានៅក្នុងពាក្យនៅក្នុងនេះ គឺថាមានតែពាក្យថា "មន្ទីរ"ទេ។ តើអ៊ីចឹងយើងអត់ដឹងទេ បើមើលឯកសារហ្នឹងទៅ យើងមិនដឹងថាមន្ទីរហ្នឹងជាមន្ទីរអ្វីទេ។

**ឆ៖** ខ្ញុំមិនដឹងថាខ្ញុំអាចអូសអេក្រង់ហ្នឹងឡើងចុះដែរឬទេ ហើយគេអូសឲ្យខ្ញុំមើល ឬយ៉ាងម៉េចដោយសារតែក្នុងហ្នឹងគឺថាកន្លែងមួយចំនួនហ្នឹងវាដាច់បាត់ហើយ។ ខ្ញុំមើលអត់ឃើញ។ ដូច្នេះហើយសូមខិតឡើងលើបន្តិចបានខ្ញុំមើល។ បាទឃើញហើយ។

**ស៖** *(គ្មានការបកប្រែ)*

**ឆ៖** *(គ្មានការបកប្រែ)*

[០៩:៣៣:១៧]

**ស៖** លោក ហេដឌ័រ យើងមានឯកសារក្រដាសជាភាសាខ្មែរ លោកអាចមើលបាននៅក្នុងក្រដាសហ្នឹង។

**ឆ៖** ជាការពិត អ្វីដែលបានបកប្រែនៅក្នុងភាសាអង់គ្លេស ពាក្យថា "មន្ទីរ"ហ្នឹង ពាក្យថា *"អូហ្វហ្វីស"* ហ្នឹង គេបកមន្ទីររហូតនៅក្នុងឯកសារនេះ។ ហើយសំណួរលោកស្រីសួរជាក់លាក់នោះ គឺ

អំពីអ្វីដែរ?

**ស៖** សូមអភ័យទោសលោក ហេដឌ័រ។ ច្បាប់ដើមនៃកិច្ចសម្ភាសន៍នោះជាភាសាខ្មែរ ឬក៏ជាភាសាអង់គ្លេស នៅពេលដែលលោកសម្ភាសលោក អៀង សារី នោះ? ខ្ញុំចង់ឲ្យលោកបំភ្លឺចំណុចនេះមួយសិន។ ខ្ញុំមើលឯកសារហ្នឹងទៅគឺថាជាភាសាខ្មែរទេ ច្បាប់ដើម ហើយគេបកប្រែជាភាសាបារាំង។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកសម្ភាសគាត់ជាភាសាខ្មែរ ឬក៏ជាភាសាអង់គ្លេសនៅពេលដែលលោកសម្ភាសលោក អៀង សារី នោះ?

**ឆ៖** ខ្ញុំសម្ភាសគាត់ជាភាសាខ្មែរ។

[០៩:៣៤:៤៣]

**ស៖** សូមអរគុណ។ ហើយអ្វីដែលលោកបានឃើញនៅលើអេក្រង់ហ្នឹងគឺជាភាសាខ្មែរហើយអ៊ីចឹងមែនទេ? សូមអរគុណ។ ដោយសារតែលោកលើកឡើងនូវការប្រែជាភាសាអង់គ្លេសអម្បាញ់មិញនោះ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺជាពាក្យខ្មែរ ហើយនិងបរិបទ។ ជាពិសេសនោះ គឺនៅពេលដែលយើងនិយាយអំពី "ប៊ុយរ៉ូ" ពីមន្ទីរនោះ ដែលមានមនុស្សពីរនាក់ គឺ ប៉ង់ និង លីម។ ដូច្នេះ ខ្ញុំចង់ដឹងថា "ប៊ុយរ៉ូ" ឬក៏មន្ទីរហ្នឹង មន្ទីរអីដែរ?

**ឆ៖** ក្រោយពីអានអត្ថបទហ្នឹង ហើយនិងបរិបទ ដែលគាត់បានប្រាប់ខ្ញុំ ឬក៏អ្នកជាច្រើននាក់នោះ បានប្រាប់ខ្ញុំជាច្រើនឆ្នាំមកហើយនោះ នៅក្នុងបរិបទនៃឯកសារកិច្ចសម្ភាសន៍ដែលខ្ញុំបានពិនិត្យមើលនៅក្នុងពេលដែលខ្ញុំធ្វើការងារនៅក្នុងតុលាការនេះ។ គឺគេមានយោងសរសេរអំពីប្រធានមន្ទីរឈ្មោះ ប៉ង់ ដែល ប្រហែលជាលោកស្រីចាំហើយ ឈ្មោះដែលលោកស្រីបង្ហាញខ្ញុំ នៅក្នុងឯកសារកាលពីម្សិលមិញនោះ គឺថាជាប្រធានខាងផ្នែករដ្ឋបាល។

[០៩:៣៦:១៥]

តាមប្រភពជាច្រើន ឬក៏តាមកិច្ចសម្ភាសន៍ជាច្រើនដែលខ្ញុំបានធ្វើឡើងដោយផ្ទាល់តែម្តង មិនមែនថា កិច្ចសម្ភាសន៍ខ្ញុំធ្វើឡើង -- កិច្ចសម្ភាសន៍ដែលធ្វើឡើងដោយតុលាការនោះទេ។ គឺមន្ទីរដូចគ្នានេះគេប្រើសំដៅលើ ស-៧១។ ជាថ្មីម្តងទៀត តាមកិច្ចសម្ភាសន៍របស់ខ្ញុំ ឯកសារសម្ភាសដោយតុលាការនិងឯកសារមិនមែនតុលាការ ចម្លើយសារភាពនោះ គឺគេបានបង្ហាញថាមន្ទីរនេះ វាជាបណ្តុំនៃមន្ទីរដែលគេ -- នៅក្នុងហ្នឹងមានច្រើន គេថាមន្ទីរ "ក" ជាដើមនោះ។ យើងឃើញមានច្រើនខុសៗគ្នា ហើយឈ្មោះរបស់បុគ្គលដែលនៅក្នុងនេះ ឈ្មោះ លីម ឬក៏ លឹម ហ្នឹង គឺគេបានយោងលើឈ្មោះហ្នឹង

នៅក្នុងកិច្ចសម្ភាសន៍ក្រោយៗមកទៀត។ ក៏ប៉ុន្តែកិច្ចសម្ភាសន៍ក្រោយៗ គេប្រើឈ្មោះហ្នឹង លីន។ តាមកិច្ចសម្ភាសន៍របស់ខ្ញុំ ខ្ញុំចាំមិនខុសនោះទេ បុគ្គលហ្នឹង គឺជាបុគ្គលដែលក្រោយមក ទទួលការងារខាងផ្នែករដ្ឋបាល គឺនៅក្នុងមន្ទីរ៨៧០ បានន័យថាគាត់ទទួលបន្ទុក ស-៧១ ខាងរដ្ឋបាល ក្រោយពេល ប៉ង់ត្រូវបានសម្លាប់ចោលនៅក្នុងឆ្នាំ៧៨ បានន័យថាក្រោយមក ប៉ង់ នេះ ជំនួសដោយបុគ្គលឈ្មោះ លឹម ហៅ លីន នេះ។ ប្រសិនបើខ្ញុំចាំមិនខុស ពីមុនគឺគាត់ជាប្រធានមន្ទីរ ក-១ ក្រោយ ស-៧១។ ដូចដែលរៀបរាប់នៅក្នុងនេះ ហើយនិងកន្លែងផ្សេងទៀត គាត់ហ្នឹងគឺជាអង្គរក្សរបស់កងការពាររបស់ ប៉ុល ពត នៅភូមិភាគពិ្លសាន។ គឺបានន័យថា គាត់ធ្វើការងារជាច្រើនឆ្នាំផងដែរ។ បុគ្គលឈ្មោះ ភុំ -- បុគ្គលដែលមានឈ្មោះ ភុំ ហើយរៀបរាប់ថា គាត់ទទួលខាងសាលា។ តាមកិច្ចសម្ភាសន៍បានបង្ហាញឲ្យឃើញថា គាត់ជាសមាជិកខាង គាត់ជាអនុប្រធានស-៧១។ គាត់មិនមែនជាអ្នកដែលដឹកនាំខាងជាន់ខ្ពស់ខាងយុវកកនោះទេ។ ហើយគាត់ក៏កាន់ខាងមន្ទីរ មានមន្ទីរមួយដែរ គាត់កាន់គឺមន្ទីរ“ក”, មិនដឹង “ក” ប៉ុន្មាននោះទេ។ ហើយគឺថាគាត់ហ្នឹងក៏ខាងចូលរួមក្នុងការជួយរៀបចំកិច្ចប្រជុំនៅក្នុងទីក្រុងភ្នំពេញផងដែរ។ សំណួរជាក់លាក់សួរអំពី ខៀវ សំផន ហ្នឹងគឺខ្ញុំភ្លេចសំណួរហើយ។ ហើយខ្ញុំក៏ភ្លេចដែរ ចំពោះកិច្ចសម្ភាសន៍ដែលខ្ញុំបានធ្វើឡើង។

[០៩:៣៩:២៥]

**ស៖** នៅក្នុងឯកសារដដែលនេះ លោក អៀង សារី លោកនិយាយអំពីមន្ទីរឧស្សាហកម្ម។ តើជាភាសាហ្នឹង គេប្រើពាក្យថា “មន្ទីរ” អ៊ីចឹងមែនទេ ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន នោះ?

**ឆ៖** បាទ។ វាមិនពិតជានិយាយថា ប្រធានមន្ទីរឧស្សាហកម្មចំអ៊ីចឹងតែម្តងទេ។ ខៀវ សំផន ក៏ជាប្រធានមន្ទីរម្នាក់ ប៉ុន្តែប្រធានមន្ទីរហ្នឹង គឺជាប្រធានមន្ទីរតែផ្នែកឧស្សាហកម្មអ៊ីចឹងទៅ គឺថាវាមិនៗច្បាស់លាស់។ បាទ គឺថាដែលកាន់ខាងឧស្សាហកម្មអីអ៊ីចឹង។

**ស៖** នៅពេលដែលលោកនិយាយអំពីស-៧១ លោកនិយាយថា វាមានទំនាក់ទំនង -- ខ្ញុំសួរសំណួររបៀបផ្សេងវិញ។ ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវ និងការសម្ភាស ក៏ដូចជាព័ត៌មានដែលលោកអាចទទួលបាននៅមុន ក្នុងអំឡុងពេល និងក្រោយពេលដែលលោកបំពេញការងារនៅ អ.វ.ត.ក នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏ក្នុងការិយាល័យសហព្រះរាជអាជ្ញា។ តើពាក្យ ស-២១ នេះ វាផ្សាភ្ជាប់ទៅនឹងមន្ទីរ៨៧០ មែនទេ?

[០៩:៤១:២៥]

**ធ៖** *(គ្មានការបកប្រែ)--*

**ស៖** ខាងមេធាវីជាតិបានប្រាប់ថា ស-២១ ប៉ុន្តែមិនមែនទេ គឺ ស-៧១ សូមឲ្យលោកឆ្លើយ។

**ធ៖** ខ្ញុំបាន -- ខ្ញុំនិយាយខាងក្រៅបរិបទតុលាការ ខ្ញុំនិយាយជាមួយមនុស្សខ្លះដែលមាននៅក្នុង បរិវេណនៃមន្ទីរបក្ស នៅមុនខែមេសា ១៩៧៥។ នៅក្នុងកិច្ចសម្ភាសន៍ទាំងនោះ ការពន្យល់មកប្រាប់ ខ្ញុំហ្នឹងគឺថា យ៉ាងហោចណាស់ក៏នៅក្នុងឆ្នាំ១៩៧១ ដែលស-៧១ គឺនិយាយអំពីមន្ទីររបស់មជ្ឈិមបក្ស -- សូមកែប្រែ ៨៧០ មន្ទីររបស់មជ្ឈិមបក្ស មានទីតាំងទាំងនៅកំពង់ចាម ទាំងនៅកំពង់ធំ។ ហើយមកដល់ ឆ្នាំ១៩៧១ មានមន្ទីរមួយទៀត គឺមន្ទីរស-៧១ ដែលមានមន្ទីរចំណុះជាច្រើនទៀត មានជាមួយ “ក”, មាន “ប”, មាន “ស”, មាន “ក.ស”។ អ្វី

ដែលគេរៀបរាប់អំពី ស-៧១ មកប្រាប់ខ្ញុំនោះ វាបែបជាមន្ទីររដ្ឋបាល ដែលអ្នកត្រូវរក្សាក្រដាស ស្លាម សាំង វិទ្យុ ឡាន ម៉ូតូ។ បាទ គឺរាល់សម្ភារៈទាំងអស់ដើម្បីឲ្យដំណើរការទៅបាននោះ ហើយ បើសិនណាពាក់ព័ន្ធនឹងរឿងនយោបាយ គឺត្រូវតែអ្នកណាដែលមានការទទួលខុសត្រូវ មានសមត្ថភាព គឺអ្នកណាដែលថៅហ្វាយ ដែលប្រធានណាអាចទុកចិត្តបាន បានឲ្យទទួលបន្ទុកផ្នែកនយោបាយ។

[០៩:៤៤:០១]

នៅក្នុងមន្ទីរស-៧១នេះ មានមន្ទីរមួយហៅថា មន្ទីរនយោបាយ ការិយាល័យនយោបាយ គឺយើង គឺប-១៧។ ដូច្នេះ យោងទៅតាមដំណើររឿងនេះ មន្ទីរស-២១ គឺថាវាមានតាំងពីឆ្នាំ១៩៧១ មកម្ល៉េះ ហើយបន្ទាប់មកក៏បានផ្លាស់ប្តូរមកភ្នំពេញ។ ដូច្នេះ ការរៀបរាប់ហ្នឹងគឺថាវាស៊ីសង្វាក់គ្នា ហើយរៀបរាប់ អំពីដំណើរការប្រព្រឹត្តទៅដូចគ្នា ហើយក្នុងនេះក៏ឃើញដូចមាននៅក្នុងឯកសារបង្ហាញពីម្សិលមិញ គឺថា មានមន្ទីរពីរត្រូវបានបង្កើតឡើងដាច់ដោយឡែកពីគ្នា។ ដែលតាមខ្ញុំយល់ពីដើមខ្ញុំអត់ដែលបានផ្តាប់ឮអំពី មន្ទីរនយោបាយ៨៧០អីអ៊ីចឹងទេ។ ដូចដែលខ្ញុំបកប្រែថា “ប៉ុយរ៉ូ” គឺមន្ទីរ៨៧០នេះ គឺថាមិនមាន -- ខ្ញុំមិនបានដឹងវាមាននៅមុនខែមេសា ៧៥ ទេ។ ប៉ុន្តែបើនិយាយអំពីស-៧១ គឺវាមានលក្ខណៈរចនាសម្ព័ន្ធ ស្រដៀងទៅហ្នឹងអ្នកដែលមានរចនាសម្ព័ន្ធនៅក្នុងបក្សកុម្មុយនីស្ត គឺចិន វៀតណាម។ គេរៀបរាប់ថា នៅចិន នៅវៀតណាមនោះ គឺជាមន្ទីររួមមួយរបស់បក្សដែលមានមុខងារស្រដៀងគ្នា។ គឺថាមន្ទីរនេះ មានតាំងពីមុនខែមេសា ៧៥ និងបន្តមានរហូតទៅដល់ក្រោយខែមេសា ៧៥។ កិច្ចសម្ភាសន៍ទាំងអស់ ហ្នឹង ទាំងដែលខ្ញុំបានធ្វើទាំងពីមុនបង្កើតតុលាការ ហើយនិងពេលខ្ញុំធ្វើការនៅតុលាការ និងក្រោយមក ទៀតហ្នឹង គឺវាមានការច្របូកច្របល់ណាស់។ ច្របូកច្របល់អំពីរវាងមន្ទីរស-៧១ និងមន្ទីរ៨៧០។ គេ

ភាគច្រើននិយាយ អ្នកខ្លះនិយាយអំពីមន្ទីរ៨៧០ ថាជាមន្ទីរស-៧១។ ដូច្នេះ ខ្ញុំមើលទៅឃើញថាវាមានភាពមិនច្បាស់លាស់ និងមានភាពច្របូកច្របល់។

[០៩:៤៦:៣៩]

មានមនុស្សជាច្រើននិយាយថា ប៉ង់ និង លឹម គឺជាមន្ទីរ៨៧០។ ពេលខ្លះ អ្នកខ្លះមានការយល់ដឹងផ្នែកខាងក្នុងហ្នឹងខ្លះដែរ ក៏និយាយថា ប៉ង់ គឺជាប្រធានស-៧១ ហើយស-៧១ ជាមន្ទីរមួយរបស់មន្ទីរ៨៧០នេះតែម្តង។ មិននិយាយថា -- វាអាចនិយាយថាមានតែមួយ ឬក៏អាចមានទាំងពីរ។ ហេតុដូច្នេះឯង បានជាវាពិបាកនឹងញែកឲ្យដាច់ពីគ្នាថាតើគេនិយាយសំដៅទៅលើមួយណា? ការនិយាយពីបុគ្គលណាម្នាក់ និយាយពីមន្ទីរ៨៧០ វាអាចមានន័យ -- បើមិនមានបរិបទឲ្យច្បាស់លាស់ទេ មិនអាចបញ្ជាក់ថាតើចង់កំពុងសំដៅនិយាយអំពីអ្វីនោះទេ?

**ស៖** នៅលើប្រធានបទដដែល ខ្ញុំសូមចូលទៅនិយាយពីសម្រង់មួយទៀតនៃចម្លើយរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងប្រធានបទនេះ គឺឯកសារ E3/37 លេខ ERN ដដែលគឺជាភាសាបារាំងគឺ 00156681, ជាភាសាខ្មែរ 00156676, អង់គ្លេសគឺ 00115679។ សំណួរដែលគេសួរទៅលោក ខៀវ សំផន៖ គឺតើលោកអាចពិពណ៌នាអំពីរចនាសម្ព័ន្ធនៃមន្ទីរ៨៧០ដែរឬទេ? ក្នុងនេះគេប្រើពាក្យថាមន្ទីរ។ ចម្លើយ៖ គឺវាជាមន្ទីរមួយនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយវាមានសមាសភាពតែពីរនាក់ទេ គឺ ឌឿន និងខ្ញុំ។ ឌឿន គឺជាប្រធាន ហើយមានសហការីច្រើនដូចជា ប៉ង់ ជាដើម ហើយគាត់ទទួលខុសត្រូវលើការងារនយោបាយ។ ចំណែកខ្ញុំវិញ ដូចដែលបាននិយាយរួចមកហើយ គឺខ្ញុំទទួលបន្ទុកខាងរៀបចំបញ្ជីតម្លៃសម្រាប់សហករណ៍ ការបែងចែកសម្ភារៈសម្រាប់ភូមិភាគតាមការណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ។ នេះមុនពេលដែលសម្តេចសីហនុ បានលាលែងពីតំណែង។ សំណួរដូចតទៅនេះ៖

[០៩:៤៩:២០]

ទាក់ទងទៅនឹងការដែលលោកនិយាយថាមន្ទីរស-៧១ អាចមានតួនាទីនយោបាយ ការិយាល័យនយោបាយ តើចម្លើយរបស់លោក ខៀវ សំផន នេះ ទាក់ទងនឹងចំណុចហ្នឹង លោកមានបានធ្លាប់ជួបចម្លើយបែបហ្នឹងជាមួយអ្នកដែលលោកសម្ភាសផ្សេងទៀតទេ មានភាពស៊ីសង្វាក់គ្នាទេ ពាក់ព័ន្ធនឹងពាក្យមន្ទីរអស់នេះ ហើយនិងពាក់ព័ន្ធនឹងការស៊ីសង្វាក់គ្នានេះ លោកធ្លាប់ជួបក្រៅពីការសម្ភាសន៍លោក ខៀវ សំផន ទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:៥០:០៧]

**លោក ឃីត វេយ៍ន័រ៖**

មេធាវីការពារក្តី គឺបានលើកឡើងខុសនូវអ្វីដែលលោកបាន -- លោក ហេដឌ័រ និយាយហើយ កាលណានិយាយអំពីស-៧១ ថាជាមន្ទីរនយោបាយ គឺលោក ហេដឌ័រ មិនបានប្រើពាក្យហ្នឹង។ គឺថា ក្រោយខែមេសា ១៩៧៥ មានការនិយាយអំពីមន្ទីរនយោបាយមួយគឺមន្ទីរ៨៧០។ អ៊ីចឹងសូមកុំលើកអ្វី កុំអ្វី--

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន អ្វីដែលខ្ញុំ -- ខ្ញុំឲ្យលោក ស្ទីវ ហេដឌ័រ បំភ្លឺចំណុចនេះតែម្តង។ តើមន្ទីរស-៧១ បើតាមរយៈការសម្ភាសជាច្រើនរបស់លោក និងការស៊ើបអង្កេតជាច្រើនរបស់លោកនោះ មានអ្នកណាដែលគេហៅពាក្យថា "មន្ទីរស-២១" -- ស-៧១ នេះជាមន្ទីរនយោបាយដែរឬទេ? អានេះតាមរយៈការស្រាវជ្រាវអង្គហេតុរបស់លោក ហើយនិងការ ឬក៏ការប្រើប្រាស់របស់មនុស្សទាំងឡាយដែលលោកបានសម្ភាសណ៍ា?

[០៩:៥១:៣៤]

**ឆ៖** ខ្ញុំអាចច្រឡំដែរ គឺឆ្លើយថាអត់ទេ។ ស-៧១ តាមដែលខ្ញុំចាំ និងតាមមនុស្សដែលខ្ញុំនិយាយជាមួយនេះគឺថា មិនមែនជាមន្ទីរនយោបាយរបស់ម៨៧០ទេ។ ដូចយើងបញ្ជាក់ពីម្សិលមិញ ក្នុងឯកសារពីម្សិលមិញវាជាមន្ទីររដ្ឋបាល។ អ៊ីចឹងមើលទៅវាដូចជាស៊ីសង្វាក់គ្នាជាមួយនឹងការរៀបរាប់របស់អ្នកដែលខ្ញុំសម្ភាសភាគច្រើន បើមិនទាំងអស់អស់ទេ។ បញ្ហាដែលខ្ញុំចង់លើកឡើងនេះ គឺថាពាក្យថាមន្ទីរ ៨៧០ នេះគឺថាមនុស្សជាច្រើនដែលខ្ញុំបានសម្ភាសទាំងពីមុនខ្ញុំធ្វើទៅតុលាការ និងក្នុងពេលខ្ញុំធ្វើទៅតុលាការ និងក្រោយពេលខ្ញុំចាកចេញពីតុលាការនេះទៅ ថា មន្ទីរ៨៧០ហ្នឹងគឺរៀបរាប់ -- ក្រោយមកបានរៀបរាប់អំពីស-៧១។ ដូច្នេះ តាមដែលខ្ញុំបានធ្វើជាញឹកញាប់នោះគឺថាអ្នកណាជាប្រធានមន្ទីរ៨៧០ ហើយតាមការពិតគឺគេនិយាយថា "អូ! ប៉ង់" ហើយអ្នកខ្លះថាអត់ចាំ។ ហើយអ្នកខ្លះថា ខ្ញុំចាំហើយ គឺឈ្មោះ លីន។ ហើយអ្នកខ្លះថា ឌឿន អ្នកខ្លះទៀតថា ខៀវ សំផន។

ដូច្នេះវាផ្ទុះបញ្ចាំងអំពីការកត់ត្រារបស់ខ្ញុំថា វាពាក់ព័ន្ធទៅនឹងពាក្យពេចន៍ដែលត្រូវប្រើនោះទេ។ គឺគេអ្វីដែលគេកំណត់ឡើងគឺដើម្បីឱ្យអ្នកខាងក្រៅហ្នឹងពិបាកគិតថា អ្នកណាធ្វើស្អី ហើយមន្ទីរហ្នឹងធ្វើស្អី អ៊ីចឹងជាដើម។

[០៩:៥៣:៤៦]

**ស៖** សូមអរគុណ។ លោកនិយាយអំពីលេខកូដដែលប្រើដើម្បីឱ្យមានការច្របូកច្របល់ តើលោកយល់យ៉ាងដូច្នេះនេះ តាមរយៈការស្រាវជ្រាវ ឬក៏តាមកិច្ចសម្ភាសន៍របស់លោក ឬក៏តាមរយៈការធ្វើការងារនៅតុលាការយើងនេះ? តើ -- ខ្ញុំចង់សួរផងដែរថាតើមានមន្ទីរផ្សេងៗទៀតហ្នឹង មានលេខកូដខុសៗគ្នាអ៊ីចឹងដែរក្រៅពីមន្ទីរ៨៧០នេះ តើមានមន្ទីរផ្សេងទៀតដែលមានភាពច្របូកច្របល់ដូចគ្នាអ៊ីចឹងទេ ឬក៏មានតែ៨៧០ហ្នឹងទេ?

**ឆ៖** ខ្ញុំយល់សំណួរនេះហើយ។ ការមាន -- ការដែលមានមន្ទីរ តាមសក្ខីកម្មដែលរាប់មិនអស់នោះ កិច្ចសម្ភាសន៍ដែលរាប់មិនអស់ គឺនិយាយអំពីរចនាសម្ព័ន្ធមួយដែលថ្នាក់ខ្ពស់។ រាល់មន្ទីរគណបក្ស ឬមន្ទីរដែលដឹកនាំដោយបក្ស ទោះបីយោធាក្ដី រដ្ឋបាលក្ដី បើយោងទៅតាមការរៀបរាប់នៅក្នុងកិច្ចសម្ភាសន៍ហ្នឹង គឺត្រូវទទួលខុសត្រូវខាងផ្នែកក្រដាសស្នាម ការចេញលិខិតអញ្ជើញឱ្យមកប្រជុំ ការរក្សាប្រេងឥន្ធនៈជាដើម។ល។ វាជា គេហៅថាជាអង្គភាពរូបវន្តមួយ គឺថានៅគ្រប់កម្រិតទាំងអស់ និងនៅគ្រប់រចនាសម្ព័ន្ធទាំងអស់ នៅកន្លែងណាក្ដី គឺយើងមានគណៈកម្មាធិការដែលដឹកនាំដោយលេខាបក្ស អនុលេខាបក្ស ឬក៏សមាជិកបក្ស។ ហើយការបម្រើនៅក្នុងគណៈកម្មាធិការមួយៗនោះ គឺមន្ទីរ ក្រោមនោះគឺមានមន្ទីរ។ ទោះបីជាប្រធានមន្ទីរហ្នឹង អាចជាសមាជិករបស់គណៈកម្មាធិការនោះក្ដី ឬក៏មិនមែនក្ដី។ នេះបើយោងតាមកិច្ចសម្ភាសន៍ហ្នឹង គឺថាវាអាចថានៅក្នុងករណីជាច្រើន គឺប្រធានមន្ទីរជាសមាជិករបស់គណៈកម្មាធិការ។ ហើយដូចដែលមានមនុស្សជាច្រើនរៀបរាប់ប្រាប់ខ្ញុំថា ប្រសិនបើអ្នកណាម្នាក់ដែលគេទុកចិត្តដែលមានជំនាញខាងផ្នែករដ្ឋបាល ឬក៏ទុកចិត្តខាងផ្នែកនយោបាយ ឱ្យមកកាន់តួនាទីហ្នឹង។ ដូចដែលយើងដឹងហើយ ការដែលមានការិយាល័យធិបតេយ្យបែបនេះ គឺថាមនុស្សដែលគេទុកចិត្តគឺជារឿងសំខាន់ណាស់។

[០៩:៥៧:១១]

អ៊ីចឹងអង្គភាពទាំងអស់នេះ វាកើតមាននៅក្នុងទូទាំងរចនាសម្ព័ន្ធរបបនោះតែម្ដង។ តាមយល់របស់ខ្ញុំគឺថាមជ្ឈិមគឺត្រូវបង្កើតតាមឯកសារ ចុះខែតុលា ៧៥នោះ គឺការបង្កើតនូវមន្ទីរនយោបាយខុសៗ

E1/226.1

គ្នាបែបនេះ។ គឺតាមដែលខ្ញុំយល់ គឺមិនមាននៅក្នុងកម្រិតផ្សេងៗទៀតទេ។ មានតែមជ្ឈិមទេ។

**ស៖** នៅក្នុងក្របខ័ណ្ឌនៃព័ត៌មានដែលលោកបានដឹង មុន ឬក៏ក្នុងអំឡុង ហើយពេលក្រោយ ពេលដែលលោកធ្វើការនៅ អ.វ.ត.ក នេះ តើមន្ទីរ អ៎! ស្ថាប័ន៨៧០នេះ ដែលលោកពិពណ៌នាអម្បាញ់មិញថាជាមន្ទីរនយោបាយនោះ។ តើលោកស្គាល់កន្លែងមន្ទីរហ្នឹងទេ? ដឹងថាទីតាំងនៅទីណាទេ នៅទីក្រុងភ្នំពេញនោះ បើតាមរយៈព័ត៌មានទាំងប៉ុន្មានដែលលោកប្រមូលបាននោះណ៎ា ដឹងទីតាំងនៅត្រង់ណាជាក់លាក់ទេ?

**ឆ៖** ថាតើ ប៉ង់ កាន់កាប់នៅថ្ងៃជាក់លាក់ណាមួយ គឺថាតាមកិច្ចសម្ភាសន៍របស់ខ្ញុំ គឺថាមានទីបញ្ជាការមួយរបស់គាត់។ វាមានអនុមន្ទីរ គឺមាន ក-១, ក-២ ។ល។ និង។ល។ ប៉ុន្តែមើលទៅ ប៉ង់ នោះហាក់បីដូចជាគាត់ធ្វើដំណើរគ្រប់កន្លែង"ក" ដូចជា ក-៧ នៅជិតមាត់ទន្លេ។ ខ្ញុំ ប៉ុន្តែតាមកិច្ចសម្ភាសន៍ហាក់បីដូចជាគាត់មិនមាន គេហៅថាកៅអីណាអង្គុយជាអចិន្ត្រៃយ៍ទេ។

[០៩:៥៩:៣៥]

**ស៖** ទាក់ទងទៅនឹងព័ត៌មានដែលលោកប្រមូលបាន ទាក់ទងទៅនឹង ប៉ង់ ហើយនិងទាក់ទងនឹងការពិពណ៌នាដែលលោកបានធ្វើ -- អម្បាញ់មិញថាបុគ្គលិកទាំងអស់នោះ ត្រូវទទួលសេចក្តីទុកចិត្តពីមេ។ តើក្នុងរយៈមុនពេល ឬក៏ក្នុងអំឡុងពេល ពេលក្រោយពេលលោកធ្វើការនៅតុលាការយើងនេះ។ តើលោកមានដឹងថា មានតាមរយៈកិច្ចសម្ភាសន៍របស់លោកទាំងប៉ុន្មានហ្នឹងលោកមានដឹងថា តើទំនាក់ទំនងរវាង ប៉ង់ និង ប៉ុល ពល ហ្នឹងយ៉ាងម៉េចដែរទេ?

**ឆ៖** នៅក្នុងកិច្ចសម្ភាសន៍មួយចំនួន -- បាទ អ្នកដែលខ្ញុំសម្ភាសនេះ បាននិយាយថាគេជឿជាក់ថាអ្នកទាំងពីរហ្នឹង គឺថាជិតស្និទ្ធនឹងគ្នាមែនទែន ហើយ ប៉ង់ នេះជាមនុស្សជំនិតរបស់ ប៉ុល ពត តាំងពីផ្នែកបញ្ជារដ្ឋបាល ហើយគេនៅនឹកឃើញថានៅពេលដែលក្នុងអំឡុងសង្គ្រាម ប៉ង់ ជាប្រធានស-៧១ ហ្នឹង គឺថាគាត់បំពេញមុខងារដូចគ្នា ស្រដៀងនឹងមន្ទីរ១០០។ បាទ គេហៅថាជាមន្ទីរនិរទេសរបស់បក្សនៅពាក់កណ្តាលទសវត្សរ៍៦០។

[១០:០១:២៣]

តាមកិច្ចសម្ភាសន៍មួយលើក ឬក៏ពីរលើកដែលខ្ញុំដែលខ្ញុំចាំ គឺថាពួកគេមានការរន្ធត់ណាស់ ហើយធ្វើឲ្យគេមានការព្រួយបារម្ភមែនទែននៅពេលគេឮសួរថា ប៉ង់ ត្រូវបានចាប់ខ្លួន ហើយចោទថាជាជនក្បត់នោះ ពីព្រោះតាមដែលគេគិតនៅក្នុងខួរក្បាលរបស់គេថា មិនអាចទៅរួចទេ។ ប៉ង់ មិនអាច

ជាៗអ្នកក្បត់ ហើយ ប៉ុល ពត ទៅជាចាប់ ប៉ង់ ហើយចោទ ប៉ង់ ថាជាជនក្បត់បែបនេះបានទេ។ ដូច្នេះ ហាក់បីដូចជាសញ្ញាបញ្ជាក់អំពីការយល់ដឹងរបស់ពួកគេ ដែលគេបានប្រាប់ខ្ញុំថា តើមនុស្សទាំងពីរនេះវាជិតស្និទ្ធនឹងគ្នាយ៉ាងណានោះ។

**ស៖** នៅ -- ក្រោយពីការចាប់ខ្លួន ប៉ង់ ហើយ ហើយទាក់ទង -- តាមរយៈព័ត៌មានដែលលោកប្រមូលមានមុនពេល ក្នុងអំឡុងពេល និងក្រោយពេលដែលលោកធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក យើងនេះ។ ដូចដែលលោក អៀង សារី បានឆ្លើយប្រាប់លោកនៅក្នុងសម្រង់មួយដែលខ្ញុំបានអានជូនលោកអម្បាញ់មិញនេះ។ តើពិតជា លីន ហ្នឹងឯងដែលមានមកជំនួស ប៉ង់ ហ្នឹង? បើតាមខ្ញុំ -- ខ្ញុំសួរថាតើព័ត៌មានដែលខ្ញុំអានអម្បាញ់មិញនេះ សម្រង់ដែលខ្ញុំអានជូនលោកអម្បាញ់មិញនេះ នេះដែលថា លីន ហ្នឹងមកជំនួស ប៉ង់ ហ្នឹងលោកមានទទួលបានព័ត៌មានដូចគ្នាហ្នឹងពីហ្នឹងដែលលោកសម្ភាសនៅកន្លែងផ្សេងទៀតទេ?

[១០:០៣:០៩]

**ឆ៖** សូមទោសខ្ញុំស្តាប់សំណួរនេះ ដូចជាយល់មិនពេញលេញទេ។

**ស៖** ខ្ញុំសួរឡើងវិញ។ អម្បាញ់មិញនេះ ខ្ញុំអានផ្នែកមួយជូនលោក សម្រង់គឺថា សម្ភាសរបស់លោកជាមួយលោក អៀង សារី។ លោក អៀង សារី និយាយអំពី ប៉ង់ ដោយនិយាយថា លីន ហ្នឹងមកជំនួស ប៉ង់ ជនជាតិចារ៉ាយ។ អ៊ីចឹងខ្ញុំសួរលោកថា សួរថាព័ត៌មានដែលលោក អៀង សារី ប្រាប់ជូនលោកនេះ មានស៊ីសង្វាក់ជាមួយនឹងព័ត៌មានដែលលោកទទួលបានក្នុងពេលដែលលោកធ្វើការ មុនពេលដែលលោកចូលធ្វើការ និងក្នុងអំឡុងពេល ហើយនិងក្រោយពេលដែលលោកធ្វើការនៅតុលាការនេះដែរឬទេ ថាពេលក្រោយដែលគេចាប់ ប៉ង់ ហើយ លីន នេះមកជំនួស?

**ឆ៖** បាទ គឺមុនពេលវៀតណាមចូលមក ចម្លើយគឺថា បាទ។ តាមប្រភពជាច្រើនទាំងពីមុនបង្កើតតុលាការ ទាំងពីពេលខ្ញុំធ្វើនៅតុលាការ គឺជាពិសេសនៅមុនពេលបង្កើតតុលាការ។

**ស៖** អរគុណ ពេលវេលាទៅមុខលឿន ហើយឥឡូវខ្ញុំសូមចូលទៅនិយាយពីប្រធានបទមួយទៀត។ មិននិយាយពីខ្លឹមសារទេ ឥឡូវនេះ ខ្ញុំនិយាយតែពីបរិបទដែលលោកសម្ភាសលោក អៀង សារី ថ្ងៃទី១៧ ធ្នូ ឆ្នាំ២០០៦ -- ៩៦ បាទ សូមទោស សូមកែប្រែ។ នៅពេលដែលលោកសម្ភាសហ្នឹងលោកបានលោកនិយាយនៅថ្ងៃទី១៥ កក្កដា។ ខ្ញុំសូមទោស ខ្ញុំសូមរកលេខយោងបន្តិច។ លោកបានត្រៀមកិច្ចសម្ភាសន៍ជាមួយលោក អៀង សារី ពីព្រោះលោកមិនអាចជួបគាត់នៅប៉ៃលិនភ្លាមទេ ដោយសារមាន

បញ្ហាក្នុងការឆ្លងព្រំដែន។ ការសម្ភាសនោះធ្វើឡើងនៅខែកញ្ញា ឆ្នាំ១៩៨៦។ តើលោកអាចរៀបរាប់អំពីគោលជំហរនយោបាយរបស់លោក អៀង សារី -- សូមទោស គឺមុខតំណាងរបស់លោក អៀង សារី នៅពេលនោះបានដែរឬទេ មុខតំណែងនយោបាយ?

[១០:០៦:០២]

**ឆ៖** ខ្ញុំគិតថានៅពេលហ្នឹង គឺនៅខែធ្នូ ១៩៨៦។ គាត់នៅតែជាអតីតនៃចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ គឺអ្នកដែលបានផ្ដាច់ខ្លួនចេញពីពួកខ្មែរក្រហម គឺនៅភាគច្រើននៅត្រីមាសទី២ នៃឆ្នាំ ១៩៨៦។

**ស៖** ដោយហេតុថាលោកនិយាយអំពីឈ្មោះចលនារបស់លោក អៀង សារី នេះ។ អ៊ីចឹងខ្ញុំសូមបង្ហាញឯកសារមួយជូនលោក ហើយសួរលោកថាលោកស្គាល់ឯកសារហ្នឹងដែរឬអត់ ហើយបានអានឯកសារហ្នឹងដែរឬអត់ មុនពេលលោកសម្ភាសលោក អៀង សារី នេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារហ្នឹងជូនទៅលោកសាក្សី គឺឯកសារ E3/86 ដែលមានចំណងជើងថា "ការពិតនៅក្រោមរបបផ្ដាច់ការរបស់ ប៉ុល ពត"។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ច្បាប់ដើមជាភាសាអង់គ្លេស។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកមានបានអានឯកសារហ្នឹងទេមុនពេលសម្ភាសលោក អៀង សារី។ ទំព័រទី១ គឺ ERN ជាភាសាបារាំង 00614092, ERN ជាភាសាអង់គ្លេស គឺ00081213 ហើយដល់ 14, ជាភាសាខ្មែរគឺ 00224429។ ជាភាសាអង់គ្លេសគឺ 0081 213។ សំណួរខ្ញុំសួរ តើលោកមានបានអានឯកសារហ្នឹង ឬក៏ស្គាល់ឯកសារហ្នឹងមុនពេលដែលសម្ភាសលោក អៀង សារី ទេ។?

[១០:០៨:៣២]

**ឆ៖** ខ្ញុំបាន។ ជាការពិត ឯកសារនេះមានចំណារបស់ខ្ញុំនៅលើហ្នឹង នៅខាងស្ដាំខាងលើហ្នឹងដាក់ថា អៀង សារី។ តុលាការនេះផ្ដល់ជូនដោយផ្ទាល់ ឬក៏ដោយប្រយោលពីខ្ញុំ ឬក៏មិនដឹងផ្ដល់ដោយផ្ទាល់ ឬដោយប្រយោលដោយ ឌី.ស៊ី.ខេម។ នេះជាឯកសារដែលខ្ញុំធ្លាប់បានធ្វើកាលពីមុន មុនពេល

ដែលជួប អៀង សារី។

**ស៖** បើខ្ញុំមិនច្រឡំទេ ពេលដែលលោកសម្ភាសជាមួយលោក អៀង សារី ហ្នឹងលោកដឹងថា មានការផ្ដាច់ខ្លួនចេញពី ប៉ុល ពត នៅពេលនុ៎ង អ៊ីចឹងមែនទេ? អ៊ីចឹងគឺប្រហែលជាបានន័យថា អ្វីដែល លោក អៀង សារី និយាយនោះគឺថាវាស្ថិតនៅក្នុងបរិបទដែលមានការផ្ដាច់ខ្លួនចេញពី ប៉ុល ពត ហើយ។ អ៊ីចឹងមែនទេ លោកបានសម្ភាសគាត់នៅក្នុងបរិបទហ្នឹង?

**ឆ៖** ជាការពិតដូច្នេះមែន។

[១០:០៩:៤៥]

**ស៖** ខ្ញុំសូមឲ្យលោកទៅផ្ទៀងផ្ទាត់ឯកសារមួយទៀត គឺឯកសារសវនាការថ្ងៃទី១៥ កក្កដា ឆ្នាំ ២០១៣ លោកបាននិយាយអំពីអត្ថបទលោកមួយទៅកាន់លោកសហព្រះរាជអាជ្ញា គឺឯកសារ E3/48។ នៅពេលនោះលោកបាននិយាយអំពីប្រភពនៃកំណត់ត្រាជើងទំព័ររបស់លោកលេខ៣៦១។ អ៊ីចឹង ខ្ញុំសូម យោងទៅនឹងឯកសារហ្នឹងគឺបេក្ខជនទាំងប្រាំពីរ។ ERN 00393581, ជាភាសាខ្មែរ 00742617 ពុំមានលេខ ERN ជាភាសាបារាំងទេ។ លោកបាននិយាយថា លោកបានដកស្រង់ពាក្យពេចន៍របស់ ឌុច នៅក្នុងកំណត់ជើងទំព័រ។ កំណត់សម្គាល់ជើងទំព័ររប់សលោកនោះ គឺថានោះជាចម្លើយរបស់ ឌុច ដូច ដែលមាននៅក្នុងអត្ថបទមួយរបស់ នេត ថាយ័រ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីយកឯកសារ E3/1915 ដែលជាអត្ថបទ មួយរបស់លោក នេត ថាយ័រ ដែលមានចំណងជើងថា “ការរៀបរាប់ដោយពិស្ដារពីការស្លាប់”។ លោក ប្រធាន ខ្ញុំសូមជូនឯកសារនេះទៅលោកសាក្សី លោកប្រធាន ជាភាសាអង់គ្លេសជូនគាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** តើលោកយោងទៅលើឯកសារហ្នឹងហើយឬ នៅពេលដែលលោកសរសេរអត្ថបទរបស់ លោកហ្នឹង?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ជាការពិតដូច្នោះមែន។

[១០:១២:៣០]

**ស៖** សំណួរខ្ញុំដូចតទៅនេះ: ក្រៅពីដកស្រង់ពាក្យសម្ដីរបស់ ឌុច ដែលនិយាយអំពីកិច្ចប្រជុំសម្ងាត់មួយដែលលោក ខៀវ សំផន ទំនងជាបានចូលធ្វើកំណត់ត្រា។ អ៊ីចឹងក្រៅពីចម្លើយរបស់ ឌុច នេះ តើលោកមានព័ត៌មានអ្វីផ្សេងទៀតទាក់ទងទៅនឹងកិច្ចប្រជុំនេះដែរឬទេ? ដែលមានការនិយាយនេះ មាននិយាយនៅក្នុងសវនាការយើងនេះផងដែរ កន្លងមកនេះ។

ខ្ញុំសូមពី -- យោងឯកសារយោងផ្សេងទៀតហ្នឹង ខ្ញុំចង់និយាយថាព័ត៌មានដែលលោកអាចទទួលបានអាចមុនពេលៗលោកធ្វើការនៅក្នុងតុលាការខ្មែរក្រហម ក្នុងអំឡុងពេល ឬក៏ក្រោយពេលលោកធ្វើការនៅតុលាការយើងនេះ។

**ឆ៖** ចំពោះបញ្ហានេះខ្ញុំមិនអាចជួយឆ្លើយបាននោះទេ ខ្ញុំមិនចាំជាក់លាក់ថាតើគេយោងជាក់លាក់ទៅលើចំណុចនេះឬក៏យ៉ាងណា ហើយខ្ញុំក៏មិនចាំថាចំណុចយោងនេះ វាយោងលើចំណុចណាខ្លះនោះផងដែរ។ សូមអធ្យាស្រ័យ ខ្ញុំមិនអាចជម្រាបបាននោះទេ។

**ស៖** ខ្ញុំសូមអរគុណ ប៉ុណ្ណឹងក៏បានដែរ។ ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីចំណុចមួយទៀត។ នៅពេលដែលលោកផ្ដល់សក្ខីកម្មនៅទីនេះ ហើយលោកនិយាយអំពីកិច្ចសម្ភាសន៍របស់លោកមួយជាមួយលោក ខៀវ សំផន ថ្ងៃទី០៤ សីហា ឆ្នាំ៩០។ កិច្ចសម្ភាសន៍របស់លោកជាមួយលោក អៀង សារី ផងដែរ លេខយោងគឺ E3/203 ជាកិច្ចសម្ភាសន៍របស់លោក ដែលលោកបាននិយាយជូនលោកសហព្រះរាជអាជ្ញាច្រើនមកហើយ។ ខ្ញុំសូមត្រឡប់មកនិយាយអំពីកាលៈទេសៈនៃការសម្ភាសហ្នឹង។ តើលោកអាចនិយាយអំពីស្ថានភាព ឬក៏កាលៈទេសៈនៅពេលដែលលោកជួបលោក ខៀវ សំផន ដែរឬទេ? តើគាត់មានមុខតំណែងអីជាផ្លូវការនៅពេលនោះ? កាលនោះ ថ្ងៃទី០៤ សីហា ឆ្នាំ៩០?

[១០:១៥:១៨]

**ឆ៖** ខ្ញុំមិនប្រាកដថាខ្ញុំចាំជាក់លាក់នោះទេ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែមុនពេលបង្កើតរដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ គាត់គឺជានាយករដ្ឋមន្ត្រីរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំមិនប្រាកដទេ ខ្ញុំត្រូវការឆែកត្រួតពិនិត្យទៅមើលឯកំណត់ហេតុរបស់ខ្ញុំ កាលវិភាគរបស់ខ្ញុំដើម្បីឲ្យច្បាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតជូនលិខិតមួយដែលលោកសាក្សីបានធ្វើជូនទៅសហចៅក្រមស៊ើប

អង្កេត គឺឯកសារ E3/514 ដោយផ្ញើទៅនៅថ្ងៃទី១១ ខែ៨ ឆ្នាំ២០០៩។ លេខERN ដែលខ្ញុំចាប់អារម្មណ៍នោះ-- អ៊ីចឹងខ្ញុំសូមមន្ត្រីតុលាការយកឯកសារនេះ ជូនទៅលោក ស្ទីវ ហេដឌ័រ។

[១០:១៦:២៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ទំព័រ ERN ជាភាសាបារាំងគឺ 00417794, ជាភាសាខ្មែរគឺ 00401657, ជាភាសាអង់គ្លេសគឺ 00380171។ គឺនៅកថាខណ្ឌទី២ ខ្ញុំសូមអានទូវឃ្លាទី២នៃកថាខណ្ឌជាភាសាបារាំង។ លោកនិយាយអំពីឯកសារដែលលោកបានផ្ញើជូនទៅសហចៅក្រមស៊ើបអង្កេត ភស្តុតាងមួយ គឺសន្និសីទរបស់លោក ខៀវ សំផន ហើយនិងកិច្ចសម្ភាសន៍នៅថ្ងៃទី០៤ សីហា ឆ្នាំ១៩៨០។ សន្និសីទព័ត៌មាន និងកិច្ចសម្ភាសន៍នោះត្រូវបានធ្វើឡើងកាលពីក្នុងពេលដែលខ្ញុំធ្វើការជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានស្រាវជ្រាវអាស៊ី និងសកលវិទ្យាល័យជូឡាឡុងកន និងជាអ្នកវិភាគកិច្ចសន្យាបម្រើការងារឲ្យការិយាល័យស្រាវជ្រាវកិច្ចការខាងក្រៅនៃការិយាល័យសម្ងាត់ និងការស្រាវជ្រាវនៃក្រសួងការបរទេសនៅសហរដ្ឋអាមេរិក និងការទទួលកិច្ចការស្រាវជ្រាវអំពីការវិវត្តន៍ផ្នែកនយោបាយសម័យនៅកម្ពុជា នៅក្នុងនាមវិទ្យាស្ថាននោះ និងការផ្គត់ផ្គង់ថវិកាដោយការិយាល័យនោះ។ សន្និសីទសារព័ត៌មាននោះបានធ្វើនៅក្នុងអំឡុងពេលដែលខ្ញុំធ្វើទស្សនកិច្ចជាមួយអ្នកបណ្ដាអ្នកសារព័ត៌មានមួយចំនួនទៀត ដែលចុះទៅកាន់ប៉ែកមួយនៅខាងខេត្តសៀមរាប និងដែលកាលនោះស្ថិតនៅក្រោយការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំបានទៅទីនោះតាមការអញ្ជើញរបស់ខ្លួនប្រចាំនៅក្នុងទីក្រុងបាងកក ប្រទេសថៃ និងជាពិសេសគឺលោក ពេជ្រ ប៊ុនរ៉េត។ ទស្សនកិច្ចរបស់ខ្ញុំមានរយៈពេល២ថ្ងៃ ស្ថិតនៅក្នុងអំឡុង២ថ្ងៃនោះ លោក ខៀវ សំផន បានធ្វើកិច្ចសន្និសីទសារព័ត៌មានជាមួយនឹងក្រុមភ្ញៀវ និងអនុញ្ញាតឲ្យអ្នកសារព័ត៌មាន ក៏ដូចជារូបខ្ញុំផ្ទាល់ធ្វើកិច្ចសម្ភាសន៍គាត់។ ក្រៅពីជួបគ្នានេះ នៅក្នុងការទទួលទានអាហារ បានជជែកក្រៅផ្លូវការជាមួយលោក ខៀវ សំផន ប៉ុន្តែពុំបានថតសំឡេងនោះទេ។ ហើយយើងអ្នកកាសែត -- មានកាសែតថតសំឡេងចំនួនពីរ។ សំណួរ--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោកមេធាវីគាត់អានសំណួរឡើងវិញបានទេលោកប្រធាន! និយាយម្តង

ទៀត។ អ្នកបកប្រែតាមអត់ទាន់អម្បាញ់មិញ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមសួរម្តងទៀត អ្នកបកប្រែ បកប្រែមិនទាន់ទេ។

[១០:១៩:៤០]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** ខ្ញុំសូមនិយាយយឺតជាងមុន ព្រោះពេលវេលាវាទៅលឿនពេក ទៅមុខលឿនពេក។ លោកនិយាយថា លោកអាចបញ្ជាក់បានដែរឬទេ ថាតើសន្និសីទកាសែតហ្នឹងបានកើតឡើងក្រោមការផ្តួចផ្តើមរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** គឺពិតដូច្នោះមែន។

**ស៖** លោក ស៊ីវ ហេងឆ័រ តើនៅក្នុងក្របខ័ណ្ឌនៃការអញ្ជើញហ្នឹងលោកមានបានពិភាក្សាជាមួយអ្នកកាសែតផ្សេងទៀតដែរឬទេ ក្នុងការសម្ភាសជាមួយនឹងអាជ្ញាធរនៅពេលនោះ?

**ឆ៖** ខ្ញុំមិនចាំថាបានធ្វើដូច្នោះនោះទេ។ ប្រសិនបើខ្ញុំបានធ្វើដូច្នោះមែន នៅពេលនេះវាទំនងធ្វើឡើងជាមួយអ្នកកាសែតពីខាងសារព័ត៌មានក្បូតូតែប៉ុណ្ណោះ ដែលខ្ញុំនៅពេលនោះធ្វើការជិតស្និទ្ធជាមួយនឹងសេវាកម្មកាសែតហ្នឹង ក៏ប៉ុន្តែខ្ញុំនៅតែឆ្ងល់មិនដឹងថាធ្វើជាមួយអ្នកណានោះទេ។ ខ្ញុំមិនចាំទេ និយាយជារួមលើបញ្ហានេះ។ បានន័យថា ប្រហែលជាជាមួយនឹងអ្នកដែលធ្លាប់ជាក្រុមសារព័ត៌មានដូចខ្ញុំដែរ ឬក៏យ៉ាងម៉េច ខ្ញុំមិនចាំទេ។

[១០:២១:២៤]

**ស៖** នៅពេលដែលលោកណែនាំខ្លួនឲ្យលោក ខៀវ សំផន ស្គាល់នោះ អ៊ីចឹងសំណួរទី១ ថាតើហ្នឹងជាលើកទី១ ហើយឬដែលលោកសម្ភាសគាត់ហ្នឹង?

**ឆ៖** ខ្ញុំជឿថាដូច្នោះមែន។

**ស៖** អ៊ីចឹងលោកមិនបានស្គាល់គ្នាពីមុនមកទេ មិនមានទំនាក់ទំនងមិត្តភាពរវាងលោកទាំងពីរនាក់ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺដូចអ៊ីចឹងមែន។

**ស៖** ខ្ញុំសួរអំមិញនេះ -- ឥឡូវខ្ញុំសួរម្តងទៀត។ លោកពុំមានទំនាក់ទំនងពិសេសណាមួយជាមួយ

លោក ខៀវ សំផន ទេនៅពេលនោះ អ៊ីចឹងមែនទេ?

**ផ៖** បាទ ខ្ញុំមិនមានទេ ខ្ញុំមិនទំនាក់ទំនងចំណងណាមួយជាមួយគាត់ពិសេសនោះឡើយ។

**ស៖** តើលោកណែនាំឲ្យលោក ខៀវ សំផន ស្គាល់នោះ នៅក្នុងឋានៈលោកជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានអាស៊ី ឬក៏ក្នុងឋានៈលោកជាអ្នកភ្នាក់ងារសម្ងាត់ ឬក៏ក្នុងឋានៈជាអ្នកកាសែត?

[១០:២២:៥០]

**ផ៖** ក្នុងនាមខ្ញុំជាអ្នកស្រាវជ្រាវដូចដែលខ្ញុំពន្យល់ពីមុនអ៊ីចឹង។ គឺថាដូចដែលខ្ញុំបានបញ្ជាក់នៅក្នុងនេះ មិនមែនក្នុងការងារនោះទេ។ ក៏ប៉ុន្តែដោយសារតែខ្ញុំទទួលមូលនិធិពីខាងក្រៅ ដូច្នេះហើយគឺខ្ញុំធ្វើការស្រាវជ្រាវ។ បានន័យថា ធ្វើការស្រាវជ្រាវសម្រាប់ស្ថាប័ន។

**ស៖** អ៊ីចឹងបានថា លោកណែនាំឲ្យលោក ខៀវ សំផន ស្គាល់ហ្នឹងក្នុងឋានៈលោកជាអ្នកស្រាវជ្រាវ អ៊ីចឹងមែនទេ?

**ផ៖** ជាការពិតដូច្នោះមែន។

**ស៖** លោក ស្ទីវ ហេដឌ័រ នៅក្នុងក្របខ័ណ្ឌ -- និយាយថាក្នុងឋានៈជាអ្នកស្រាវជ្រាវនេះ លោក ខៀវ សំផន បានផ្តល់ខ្លួនឲ្យគេសម្ភាសដូចដែលគាត់ផ្តល់សម្ភាសឲ្យអ្នកផ្សេងទៀតដែរ។ ដូចដែលលោកមានសរសេរនៅក្នុងលិខិតមួយ លោកបានផ្ញើជូនសហចៅក្រមស៊ើបអង្កេតហ្នឹងអ៊ីចឹង តើអ៊ីចឹងមែនទេ?

**ផ៖** អ៊ីចឹងមែន។

**ស៖** នៅក្នុងសន្និសីទកាសែតដែលលោកបានចូលរួមនោះ តើអាជ្ញាធរនៃបក្សកុម្មុយនីស្តនោះបាននិយាយអ្វីខ្លះ? ហើយគាត់ -- គេបានផ្តល់មូលហេតុអ្វីខ្លះ? ហេតុអ្វីបានគេអញ្ជើញអ្នកកាសែតមកចូលរួមសន្និសីទកាសែតហ្នឹង?

[១០:២៤:៣៥]

**ផ៖** សន្និសីទសារព័ត៌មាននាពេលនោះ តាមខ្ញុំចាំ គឺធ្វើឡើងដោយ ខៀវ សំផន និងមានវត្តមានអ្នកផ្សេងទៀត គឺបានន័យថា សន្និសីទស្តីអំពីការតស៊ូប្រឆាំងនឹងវៀតណាម។ បានន័យថា ស្ថានភាពក្រោយឆ្នាំ១៩៧៩ នាពេលនោះ។

**ស៖** អ៊ីចឹងគឺជាសន្និសីទកាសែតទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធនៅពេលនោះ។ អ៊ីចឹងយើងយល់ ឯកភាពគ្នាទេ ត្រង់ចំណុចនេះ?

**ផ៖** បាទ ខ្ញុំឯកភាព។

**សៈ** នៅក្នុងការសន្ទនាគ្នាជាមួយលោក ខៀវ សំផន ហើយនិងជាមួយអាជ្ញាធរផ្សេងៗទៀតនោះ តើគោលបំណងនៃខ្លឹមសារដែលគេនិយាយប្រាប់នោះ គឺជាការបង្រួបបង្រួមគ្នាដើម្បីប្រឆាំងនឹងវៀតណាម។ ខ្ញុំចង់និយាយថា ខ្លឹមសារនៃពាក្យពេចន៍ដែលគាត់បាននិយាយនៅពេលនោះ អាជ្ញាធរផ្សេងៗទៀត ក៏ដូចជាលោក ខៀវ សំផន ដែរហ្នឹង គាត់ហ្នឹងគឺថាចង់ឲ្យបានសមគ្គីគ្នាដើម្បីប្រឆាំងវៀតណាម។ អ៊ីចឹងមែនទេ បើសរុបឲ្យខ្លី?

[១០:២៦:០២]

**ឆៈ** ឯកសារភាពការរួបរួមគ្នារវាង ខៀវ សំផន នៅម្ខាង ហើយបានន័យថាការរួបរួម និងការឯកភាពគ្នានៅខាងខ្ញុំជាអ្នកសារព័ត៌មានឬយ៉ាងម៉េច? ខ្ញុំអត់យល់ជាក់លាក់នឹងសំណួរដែលទៅដល់សួររូបខ្ញុំនេះផង។

**សៈ** ឥឡូវខ្ញុំសូមសួរឲ្យច្បាស់ជាងហ្នឹង។ នៅពេលដែលឥស្សរជននៃរបបកម្ពុជាប្រជាធិបតេយ្យនិយាយទៅកាន់លោកនោះ គឺថាពួកគេចង់ប្រាប់ថាគេមានឯកភាពគ្នាដើម្បីប្រឆាំងនឹងវៀតណាម អ៊ីចឹងមែនទេ?

**ឆៈ** ប្រសិនបើលោកស្រីមានន័យថា វាលេចចេញពីសម្ដីរបស់ ខៀវ សំផន នៅក្នុងសន្និសីទកាសែត និងអ្វីដែលអ្នកនៅក្នុងពេលធ្វើសម្ភាស ធ្វើសន្និសីទនិយាយក្រៅបរិបទនោះ យើងហាក់ដូចជាឃើញថា គេឯកភាពគ្នាចង់បណ្ដេញវៀតណាមចេញ។ ចំណុចហ្នឹងគឺអ៊ីចឹងមែន។

ខ្ញុំមិន -- ខ្ញុំបាននិយាយកាលពីថ្ងៃមុន គឺក្នុងនោះបានន័យថាមាន សុន សេន ក៏មានវត្តមាន និងមានពីរនាក់ទៀតបានន័យថា តាមព័ត៌មានគឺពិតដូច្នោះមែន ឯកភាពគ្នាថានឹងចង់បណ្ដេញវៀតណាមចេញ។

[១០:២៧:៣៧]

**សៈ** អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថាហ្នឹងជាប្រធានបទចម្បងនៃសន្និសីទកាសែតហ្នឹង គឺថាកាលណោះ គោលបំណងគឺចង់និយាយអំពីការលុកលុយរបស់វៀតណាមតែប៉ុណ្ណោះ អ៊ីចឹងមែនទេ?

**ឆៈ** គឺលើកឡើងដូច្នោះមែន។

**សៈ** នៅពេលដែលលោកបានពិភាក្សា ឬក៏សម្ភាសជាមួយលោក ខៀវ សំផន នោះតើគាត់បាននិយាយអ្វីឲ្យជាក់លាក់ទេ ក្នុងការបង្រួបបង្រួមសាមគ្គីគ្នានៅពេលនោះ នៅពេលដែលប្រទេសហ្នឹងកំពុងតែមានសង្គ្រាម?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប? សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការសំណួរ សួរសំណួរនេះ គឺថាតើសួរសំណួរនេះពាក់ព័ន្ធនឹងអ្វី គឺឱ្យលោក ស្ទីវិន ហេដឌ័រ លើកឡើងទាយស្មានទៅលើអ្វី ខៀវ សំផន នាពេលនោះលើកឡើង ឬក៏យ៉ាងម៉េច? ខ្ញុំគិតថាសំណួរនេះមិនពាក់ព័ន្ធទេ ខ្ញុំសូមជំទាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ភាពពាក់ព័ន្ធគឺថាដូចសំណួរមុនៗអ៊ីចឹង គឺថាខ្ញុំសួរចង់បានបរិបទ ខ្លឹមសារនៃកិច្ចសម្ភាសន៍នោះ នៅពេលដែលយើងស្តាប់សក្ខីកម្មហ្នឹងគឺ--

**អ្នកបកប្រែ៖**

លោកប្រធានសុំឱ្យមេធាវីគាត់និយាយម្តងទៀត លោកប្រធាន ព្រោះអ្នកបកប្រែតាមអត់ទាន់ទេ។

[១០:២៩:២២]

**កញ្ញា អង់តា ហ្គីសសេ៖**

សំណួរខ្ញុំសួរចង់ដឹងថា គឺថាបរិបទសង្គ្រាមមាននៅពេលនោះ ថាតើលោក ស្ទីវ ហេដឌ័រ នេះនៅពេលដែលគាត់ចោទសួរសំណួរអីនោះ គាត់មានរំពឹងចាំថាមានការសាមគ្គីគ្នា នៅពេលការ ឬក៏ការបែកបាក់គ្នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។ ខ្ញុំចង់ដឹងថានៅក្នុងបរិបទនុ៎ង តើគាត់អាចខ្លឹម --ធ្វើការវាយតម្លៃលើខ្លឹមសារនៃពាក្យពេចន៍មនុស្សដែលគាត់សម្ភាសហ្នឹងយ៉ាងម៉េច?

ដោយសារពេលវេលាទៅមុខហើយ ខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះអាចផ្តល់ពេលជូនខ្ញុំ១០នាទីទៀតបានដែរឬទេ? នៅថ្ងៃទី១១ កក្កដា ឆ្នាំ២០១៣ នៅម៉ោង ១៥:៣៨នាទី លោកសាក្សីលោកបានឆ្លើយទៅសហព្រះរាជអាជ្ញាថា អំពីអត្ថបទរបស់លោកសរសេរពី ប៉ុល ពល និង ខៀវ សំផន គឺឯកសារ E3/3169 ហើយកំណត់សម្គាល់ជាភាសាអង់គ្លេសគឺទំព័រ២៨, ERN ជាភាសាបារាំងគឺ 00722089, ERNជាភាសាអង់គ្លេស 00002770, ERN ជាភាសាខ្មែរគឺ 00711413។ នៅក្នុងផ្នែកហ្នឹង នៅពេលដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញា លោកនិយាយថា ត្រូវតែលើកពាក្យពេចន៍របស់លោក ខៀវ សំផន ឡើងវិញ នៅពេលដែលលោកសម្ភាសគាត់ពីមុនមក។ ហើយនិងលើកឯកសារដែលបានបោះពុម្ពដោយមានការអនុញ្ញាតពីគាត់ នៅឆ្នាំ១៩៨៧។

[១០:៣១:២៦]

ឯកសារ កក្កដា ឆ្នាំ១៩៨៧នេះ ខ្ញុំសូមផ្តល់ឯកសារជូនទៅលោកសាក្សី គឺឯកសារ E3/703 ហើយខ្ញុំចង់ដឹងថា តើលោកសាក្សីយោងទៅឯកសារហ្នឹងឬ នៅពេលដែលលោកបោះពុម្ពសៀវភៅមួយ ដែលលោកទទួលបានការអនុញ្ញាតពីលោក ខៀវ សំផន កាលណោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងលោកប្រធាន ខ្ញុំសូមអនុញ្ញាតសុំឲ្យលោកមន្ត្រីតុលាការយកឯកសារនេះជូនគាត់ គឺចំណង ជើងថា៖ ការពិតនៃការកាប់សម្លាប់ដែលកើតឡើងចន្លោះឆ្នាំ៧៥ ទៅដល់ឆ្នាំ១៩៧៨។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ទំព័រទី១នៅក្នុងគ្រប់ភាសាទាំងអស់ នៅភាសាបារាំងគឺ ERN 00093791, ERN ជាភាសាអង់គ្លេស 0003999, ភាសាខ្មែរគឺ 00700545។ លោកសាក្សី នៅពេលដែលលោកដកស្រង់ពាក្យពេចន៍របស់លោក ខៀវ សំផន នេះ តើលោកយោងទៅលើឯកសារខែកក្កដា ឆ្នាំ១៩៨៧នេះទេ? គឺថាការិយាល័យឧបនាយករដ្ឋមន្ត្រីកម្ពុជាប្រជាធិបតេយ្យដែលទទួលបន្ទុកកិច្ចការបរទេស។ ឯកសារហ្នឹងមែនទេ ដែលលោកយោងដើម្បីសរសេរអត្ថបទលោកនេះ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ពិតជាដូច្នោះមែន។

[១០:៣៣:២៣]

**ស៖** បើខ្ញុំមិនច្រឡំទេ ពេលសរសេរថាបោះពុម្ពដោយមានការអនុញ្ញាតនៃការិយាល័យឧបនាយករដ្ឋមន្ត្រីការបរទេស អ៊ីចឹងមែនទេ? ដោយសារថាកាលណោះ គឺថាគាត់មានតំណែងហ្នឹង ហើយអ៊ីចឹងគាត់ផ្តល់ការអនុញ្ញាតឲ្យលោកបោះពុម្ព។ អ៊ីចឹងមែនទេ?

**ឆ៖** គឺពិតដូច្នោះមែន។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់មក -- ឥឡូវខ្ញុំលោតចូលទៅចំណុចផ្សេងមួយទៀត។ ក្រៅពី *(ឮមិនច្បាស់)* ថាឧបរដ្ឋមន្ត្រីក្រសួងការបរទេសនេះ អនុរដ្ឋមន្ត្រីក្រសួងការបរទេស តើលោកបានអានឯកសារហ្នឹងមុនពេលដែលលោកធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើប

អង្កេតនៅតុលាការយើងនេះ។ ខ្ញុំសួរថាតើលោកដឹងទេថាអ្នកណាអ្នកសរសេរឯកសារហ្នឹង អត្ថបទហ្នឹងពិតប្រាកដនោះ? តើលោក ខៀវ សំផន ជាអ្នកចូលរួមក្នុងការសរសេរអត្ថបទហ្នឹងដែរឬទេ លោកមានទទួលព័ត៌មានខ្លះទេទាក់ទងនឹងអ្នកគាត់តែងអត្ថបទហ្នឹង?

**ផ៖** ខ្ញុំអត់ចាំទេ គឺអត់ចាំ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវនេះម៉ោងដប់ខ្វះម្ភៃនាទី ខ្ញុំនៅសល់សំណួរមួយទំព័រទៀត ហើយខ្ញុំមានឯកសារមួយចង់បង្ហាញជូនទៅលើ ហេដឌ័រ ជាសុន្ទរកថារបស់លោក ប៉ុល ពត ដែល -- តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរបួនដប់នាទីទៀតទេ លោកប្រធាន? ១០នាទី *(គ្មានការបកប្រែ)* ។

[១០:៣៥:៤៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៧:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ មុនពេលលោកប្រធានឆ្លើយតបទៅនឹងសំណើសុំពេលវេលាបន្ថែមស្នើឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន លោកប្រធានស្នើសុំខ្ញុំឲ្យបញ្ជាក់បំភ្លឺចំណុចមួយចំនួនដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះតាមរយៈអ៊ីម៉ែល។ ចំណុចទី១ គឺថាគឺលើកឡើងបញ្ហាពាក់ព័ន្ធនឹងចំណុចដែលត្រូវពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះ ជាពិសេសនៅពេលដែលបិទការពិភាក្សាដេញដោលលើភស្តុតាង។ បានន័យថា អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាអាទិត្យក្រោយ ដើមអាទិត្យក្រោយឲ្យលើកឡើង ក៏ប៉ុន្តែមានបញ្ហាមួយទៀត បន្ថែមដែលទើបតែបានលើកឡើងសហព្រះរាជអាជ្ញាចង់លើកឡើងថា ក្រោយពេលពិនិត្យទៅលើ -- ពិនិត្យដោយក្រុមមេធាវីការពារក្តី ខៀវ សំផន ទៅលើសាក្សីរូបនេះ។ សួរទៅខាងសហព្រះរាជអាជ្ញាត្រូវការពេលវេលាប៉ុន្មាន?

[១០:៣៨:៤២]

**លោក អាប់ឌុលឡាក់ ចារីក៖**

ចំពោះបញ្ហាទី២បន្ថែមនេះ គឺថាយើងមិនត្រូវការលើសពី២០នាទីទេ បានន័យថា ចន្លោះ១៥ ទៅ

២០នាទី តែប៉ុណ្ណោះ។ ច្រើនបំផុត គឺ២០នាទី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា ដែលបានព័ត៌មានជាក់លាក់នេះ។

ហើយអង្គជំនុំជម្រះសូមជម្រាបលោកស្រី អ៊ំ! ខាងក្រុមមេធាវីការពារក្ដី ខៀវ សំផន ថា អង្គជំនុំជម្រះបន្ថែមជូន១០មីនុតក្នុងការសួរសាក្សី ស៊ីវ ហេងឌ័រ នេះតាមការស្នើសុំចុងក្រោយរបស់លោកស្រី។ ប៉ុន្តែឥឡូវនេះក៏ដល់ពេលសម្រាកហើយដែរ ហើយម្យ៉ាងទៀតក៏មានបញ្ហានឹងអាចលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា ដូចគាត់បានបង្ហាញជំហរអម្បាញ់មិញនេះផង ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោល ស៊ីវ ហេងឌ័រ បញ្ចប់ ដែលអង្គជំនុំជម្រះផ្ដល់ពេលវេលា១០នាទីចុងក្រោយនេះ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ស្ទីវ ហេដឌ័រ យើងចូលមកដល់ទីបញ្ចប់នៃការសួរសំណួរហើយ។ ខ្ញុំចង់និយាយពីចំណុចមួយនៅសវនាការថ្ងៃទី១១ កក្កដា នៅម៉ោង១៥:៣៣ សហព្រះរាជអាជ្ញាបាននិយាយជាមួយលោកអំពីសុន្ទរកថារបស់ ប៉ុល ពត នៅឆ្នាំ១៩៧៧។ សុន្ទរកថានេះ ទាក់ទងជាមួយនឹងអត្ថបទរបស់លោកមួយដែលនិយាយអំពី ប៉ុល ពត, ខៀវ សំផន គឺឯកសារ E3/3169 ហើយកំណត់សម្គាល់ជើងទំព័រ៦៥ ដែលលោកនិយាយអំពីសុន្ទរកថាដែលមានចំណងជើងជាភាសាអង់គ្លេស។ ខ្ញុំសូមនិយាយជាភាសាអង់គ្លេស។

[១១:០៣:០៥]

*(អានភាសាអង់គ្លេស៖)* "ជយោ! ខួបលើកទី៧នៃបក្សកុម្មុយនីស្តកម្ពុជា។ សុន្ទរកថារបស់ ប៉ុល ពត លេខាគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាថ្លែងនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ៧៧"។

អម្បាញ់មិញ ខ្ញុំគួរតែដកស្រង់ជាភាសាបារាំង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតជូនឯកសារ E3/144 នេះទៅលោកសាក្សី។ ហើយខ្ញុំសូមដកស្រង់សម្រង់ពីរពីអត្ថបទនេះ ឯកសារនេះលោកប្រធាន។ សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សម្រង់ទី១នៅលេខ ERN S -- ជាភាសាបារាំង S00012477, ជាភាសាអង់គ្លេសគឺ 0012669, ជាភាសាខ្មែរគឺ 00019256។ ហើយនិងទៅទំព័របន្ទាប់ទៀត។ ប៉ុន្តែមុននឹងអានសម្រង់នេះខ្ញុំសូមអភ័យទោស សូមពីរបី -- មួយភ្លែត។ ខ្ញុំសូមអានសម្រង់ទី១នេះ ប៉ុន្តែជាបឋម តើលោកសាក្សីអាចបញ្ជាក់បានទេថា គឺសុន្ទរកថាហ្នឹងហើយដែលលោកសរសេរនៅក្នុងកំណត់សម្គាល់ជើងទំព័ររបស់លោកនោះ? លោកយោងទៅលើសុន្ទរកថាហ្នឹងមែនទេ? លោកសរសេរកថាខណ្ឌមួយ នៃសៀវភៅដែលពាក់ព័ន្ធនឹង ប៉ុល ពត នេះ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ជាការពិត សុន្ទរកថា ក៏ប៉ុន្តែមិនមែននៅក្នុងឯកសារនេះ ខ្ញុំបាននិយាយនៅក្នុងសក្ខីកម្ម

របស់ខ្ញុំនៅក្នុងឯកសារជាភាសាខ្មែរ មិនមែននៅក្នុងឯកសារបកប្រែជាភាសាអង់គ្លេសនេះឡើយ។

[១១:០៥:៤០]

**ស៖** អ៊ីចឹងលោកចង់បានឯកសារជាភាសាខ្មែរ ក៏ប៉ុន្តែទោះយ៉ាងណាក្តី យើងនឹងបញ្ចាំងឯកសារជាភាសាខ្មែរ។ អ៊ីចឹងលោកយោងទៅឯកសារខ្មែរនេះស្រួលជាង។

អ៊ីចឹងផ្នែកដែលខ្ញុំផ្តល់លេខ ERN អម្បាញ់មិញហ្នឹង គឺថានៅកថាខណ្ឌចុងក្រោយគេ។ "ប៉ុល ពត បានពន្យល់អំពីប្រធានបទនៃសុន្ទរកថារបស់គាត់។ នេះជាសំណូមពរដែលស្នើសុំឡើង។ ដូច្នេះ មិនមែនគ្រាន់តែជាមីទ្ទិងសម្រាប់តែបំផុសមួយភ្លែត មួយពេលដើម្បីយើងត្រឡប់ទៅវិញបំពេញភារកិច្ចយើងធម្មតាទេ។ នេះជាមីទ្ទិងរៀនសូត្រពិសោធន៍នៃចលនាបដិវត្តយើង ក្រោមការដឹកនាំរបស់បក្ស"។ សូមបញ្ចប់ការដកស្រង់។

តើនៅក្នុងសំដៅដែលលោកបានអាននេះ តើមានកថាខណ្ឌហ្នឹងមែនទេ? ហើយវាដូចគ្នានឹងរបៀបដែល ឬក៏ខ្លឹមសារនៃសុន្ទរកថាហ្នឹងទាក់ទងទៅនឹងការអភិវឌ្ឍបក្សកុម្មុយនីកម្ពុជា ដំណើរការបក្សកុម្មុយនីស្តជាដើមនេះ។ តើវាដូចគ្នាទេ? ស៊ីសង្វាក់គ្នាទេ?

**ឆ៖** ជាការពិត ខ្ញុំគិតថាដូច្នោះមែន ពិតជាដូច្នោះមែន។

[១១:០៧:២៤]

**ស៖** មុននឹងចូលទៅសម្រង់ទី២ ខ្ញុំសូមអានផ្នែកមួយទៀតនៃអត្ថបទរបស់លោកទាក់ទងទៅនឹង ប៉ុល ពត និង ខៀវ សំផន។ ហើយសុន្ទរកថានេះ សហព្រះរាជអាជ្ញាគាត់បានអានហើយៗនៅក្នុងសវនាការយើងនេះ។ ERN ដូចតទៅនេះ៖ ជាភាសាបារាំងគឺ 00722081, ជាភាសាអង់គ្លេសគឺ 0002762, ជាភាសាខ្មែរគឺ 00711397។ លោកនិយាយអំពីសុន្ទរកថានេះដូចតទៅនេះ៖ នៅក្នុងសុន្ទរកថាដែលថ្លែងដោយ -- នៅកថាខណ្ឌជិតចុងក្រោយ នៅចំកណ្តាលសុន្ទរកថាហ្នឹង។ នៅក្នុងសុន្ទរកថាដែលថ្លែងនៅថ្ងៃទី២៧ កញ្ញា ឆ្នាំ១៩៧៧ មានរៀបរាប់ពិស្តារអំពីទស្សនៈរបស់ ប៉ុល ពត លើប្រវត្តិសាស្ត្រទាំងមូលនៃចលនាកុម្មុយនីស្តកម្ពុជា និងជោគជ័យ និងបរាជ័យរបស់ខ្លួន។ ប៉ុល ពត ដូចជាផ្តល់សញ្ញាទុកចិត្តជាសាធារណៈដល់បុរសពីរនាក់ដែលបានជួបជួយជ្រោមជ្រែងគាត់ក្នុងដំណើរការបោសសម្អាត និងដែលបានផ្តើមឡើងនៅដើមឆ្នាំ។ បុរសទាំងពីរនាក់នោះ គឺលោក នួន ជា និងលោក ខៀវ សំផន។ ពួកគេគឺជាអ្នកដឹកនាំបក្សតែពីរនាក់ប៉ុណ្ណោះ ដែលលោក ប៉ុល ពត មានឱកាសលើកឡើងប្រកបដោយការពេញចិត្ត។ លោក ប៉ុល ពត បានពិពណ៌នាលោក ខៀវ សំផន ថា ជាបញ្ញវន្ត

ឧដុង្គឧត្តម និងលើកការសរសើរពីរបៀបដែលគាត់ត្រូវចាប់ខ្លួន ឃុំខ្លួន។ នៅក្នុងសុន្ទរកថារបស់ ប៉ុល ពត នេះ គាត់និយាយពីលោក ខៀវ សំផន គឺឯកសារ E3/144។ លេខ ERNដូចតទៅ S00012485 ជាភាសាបារាំង, ជាភាសាអង់គ្លេសគឺ 00012674, ជាភាសាខ្មែរ 00019271។

[១១:០៩:៤៦]

ផ្នែកដែលគាត់និយាយអំពី ខៀវ សំផន ដោយហៅ ខៀវ សំផន ដោយឈ្មោះគាត់ ហៅថាជាសមមិត្តប្រធានគណៈប្រធានរដ្ឋ។ ជាភាសាបារាំងនៅជួរទី២ នៅកថាខណ្ឌទី៣ ទំព័រទី២៥ “សមាជ -- មហាសន្និបាតតំណាងបក្សទូទៅលើកទី១ បានបើកឡើងនៅថ្ងៃទី៣០ កញ្ញា ឆ្នាំ១៩៦០ នៅទីក្រុងភ្នំពេញ ក្នុងសភាពការណ៍តឹងតែង ដែលខ្លាំងរាតត្បាតជាបន្តបន្ទាប់។ ខ្ញុំយោង ឧទាហរណ៍ថាសមមិត្តដែលជាបញ្ញវន្តធំៗ ត្រូវខ្មាំងរាតត្បាតដែរ។ បើជាបញ្ញាជនធំៗត្រូវខ្មាំងរាតត្បាតហើយ ត្រឹមពលករ កម្មករ កសិករ អ្នកធម្មតាខ្មាំងរាតត្បាតគ្មានញញើតទេ”។ ក្នុង -- សូមបញ្ចប់ការដកស្រង់។

សំណួរខ្ញុំដូចតទៅនេះ តើដែលឈរលើមូលដ្ឋាននៃសម្រង់នេះហើយ នៃសុន្ទរកថារបស់ ប៉ុល ពត នេះដែលលោកបានសរសេរឃ្លាមួយចំនួនទាក់ទងទៅនឹងពាក្យពេចន៍ថាជាគេ ថា ខៀវ សំផន នេះ ជាបញ្ញាជនគួរឲ្យគោរព ហើយនិងបញ្ញាជនដ៏ឧត្តុង្គឧត្តម។ តើលោកយោងទៅលើផ្នែកហ្នឹងឬដើម្បីសរសេរអត្ថបទលោកនោះ កថាខណ្ឌលោកមួយនៅក្នុងអត្ថបទលោក?

**ឆ៖** ជាពិតដូច្នោះមែន។

[១១:១១:៣៦]

**ស៖** អ៊ីចឹងយើងឯកភាពទេថាគ្នាទេ ថានៅក្នុងសម្រង់ដែលខ្ញុំទើបនឹងអានអម្បាញ់មិញនេះ គឺថាអានសុន្ទរកថា ប៉ុល ពត នេះដែលគាត់និយាយអំពីស្ថានភាពនៅសម័យនោះនៅឆ្នាំ១៩៦០ ហើយគាត់លើកឧទាហរណ៍អំពីស្ថានភាពរបស់លោក ខៀវ សំផន ដើម្បីនិយាយអំពីស្ថានភាពរបស់បញ្ញាជនធំៗ។ អ៊ីចឹងតើលោកយល់ស្របនឹងខ្ញុំទេថា កថាខណ្ឌនេះនិយាយអំពីបរិបទប្រវត្តិសាស្ត្រនៅពេលនោះ?

**ឆ៖** សូម ខ្ញុំសូមមើលឯកសារជាភាសាខ្មែរម្តងទៀត។

**កញ្ញា អង់តា ហ្គីសសេះ**

ឥឡូវខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងអត្ថបទជាភាសាខ្មែរនេះជូនលោកសាក្សីលោកប្រធាន។ អម្បាញ់មិញខ្ញុំភ្លេចបញ្ជាក់ថា កំណត់ហេតុសវនាការជាភាសាខ្មែរនេះមិនមានលេខ E3/144 ទេ ប៉ុន្តែគឺលេខ 4.40 ដោយសារនេះជាលេខកូដចាស់។ នេះដើម្បីកំណត់ហេតុប្រតិចារឹក។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការជួយ*សើរ*គាត់បន្តិចទៅ ដើម្បីឲ្យចំអក្សរដែលអាចមើលបាន ឬក៏ខាងបុគ្គលិកជំនួយការអាច--

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកបានមើលខ្លឹមសារជាភាសាខ្មែរនៅ? ឥឡូវខ្ញុំសូមសួរសំណួរឡើងវិញ។ នៅក្នុងអត្ថបទរបស់លោកហ្នឹង គឺថាជាការសរសើររបស់លោកលើលោក ខៀវ សំផន។ ក៏ប៉ុន្តែខ្ញុំសួរថាតើនេះមិនមែនជាការរំឭកអំពីបរិបទប្រវត្តិសាស្ត្រនៅទីក្រុងភ្នំពេញ ធៀបនឹងបញ្ញវន្តទេឬ គឺស្ថានភាពបញ្ញវន្តពេលនោះ ឆ្នាំ៦០ លោក?

[១១:១៤:៥៨]

**លោក ស៊្វីវ ហេងផ័រ៖**

**ឆ៖** ជាការពិតចំណុចនេះ គឺយោងសំដៅទៅលើស្ថានភាពដែលកើតឡើងនៅក្នុងពេលសន្និបាតនាពេលនោះ គឺនៅក្នុងខែកញ្ញា ឆ្នាំ១៩៦០។ ហើយថ្ងៃនោះ គឺថ្ងៃហ្នឹង គឺវាជាប់ទាក់ទងទៅនឹងការដែលអាចឲ្យបកស្រាយថា នៅក្នុងនេះគឺថាវាមិនមានពហុវចនៈ មិនមានកាលកំណត់ថា វានិយាយនៅពេលណានោះទេ។ សមមិត្តនេះ ត្រូវបានគេរៀបរាប់ថា ជាបញ្ញាជនចម្បងធំមួយ ហើយចំពោះខ្ញុំគឺវាបង្ហាញបច្ចុប្បន្នកាលនៅពេលនោះ សំដៅទៅលើអតីតកាលទៅវិញទេ ឬក៏បុគ្គលនោះ គឺសំដៅលើបុគ្គលនោះក្នុងឆ្នាំ១៩៦០ ឬក៏សំដៅលើឆ្នាំ១៩៧៧ ក៏ប៉ុន្តែខ្ញុំអាចយល់ថា នៅពេលគេសំដៅលើបុគ្គលហ្នឹង បុគ្គលហ្នឹងសំដៅទៅលើបុគ្គលនៅក្នុងឆ្នាំ១៩៧៧ ខែកញ្ញា នោះទេ។ ក៏ប៉ុន្តែវាអាស្រ័យទៅលើសកម្មភាពបានសរសេរ និងអនុវត្តនៅពេលនោះ។

**ស៖** សូមបញ្ចប់ចំណុចហ្នឹង គឺថាកថាខណ្ឌបន្ទាប់ទៀត។ ធៀបនឹងការសង្ស័យដែលលោក --ការមន្ទិលរបស់លោកទាក់ទងនឹងការគោរព ស្ងើចសរសើរលោក ខៀវ សំផន ពេលនោះ លោក -- ប៉ុល ពត និយាយថា៖ “បើសិនជាខ្លាំងមិនញញើតសម្លាប់បញ្ញវន្តផង វាតត្បាតបញ្ញវន្តផង អ៊ីចឹងត្រឹមកម្មករកសិករ អ្នកធម្មតាហ្នឹងខ្លាំងវាតត្បាតយ៉ាងណាទៅ”។ ហើយបន្ទាប់ទៀត កថាខណ្ឌបន្ទាប់ទៀត ខ្ញុំចង់បង្ហាញបរិបទលោក “គឺនៅក្នុងស្ថានភាពហ្នឹងហើយដែលយើងបើកមហាសន្និបាទទី១ នៃបក្សយើងនៅរ៉ាវទេះភ្លើងនៅភ្នំពេញ”។ ឥឡូវយើងគិតពីបរិបទទាំងអស់ហ្នឹង កថាខណ្ឌទាំងប៉ុន្មានច្របាច់បញ្ចូលគ្នា

ហ្នឹង នៅពេលដែល ប៉ុល ពត និយាយអំពីបញ្ហាជនធំៗ ថាអង្គាល់ហ្នឹងគាត់និយាយអំពីស្ថានភាព ឬ បរិបទនៅសម័យនោះទេ។ មិនសំដៅលើ ខៀវ សំផន ជាបុគ្គលម្នាក់នោះទេ។ អ៊ីចឹងមែនទេ? គាត់និយាយជាទូទៅណ៎ះ ខ្ញុំចង់និយាយអ៊ីចឹង។

[១១:១៧:៤៧]

**ឆ៖** តាមការយល់របស់ខ្ញុំ អានរបស់ខ្ញុំ គឺមិនមែនទេ គឺវាសំដៅទៅលើអ្នកមានវត្តមាននៅក្នុងនោះ ដែល -- ក៏ប៉ុន្តែការសរសេរនោះ គឺយើងទៅអតីតកាលទេ។ ហើយគេគ្រាន់តែសរសេរហ្នឹង ក្នុងន័យដែរវាជាបច្ចុប្បន្នកាល ក៏ប៉ុន្តែលោកស្រីអាចថាចំណុចហ្នឹងវាខុសគ្នាតាមការយល់របស់ខ្ញុំ គឺអត្ថបទហ្នឹង គេរៀបឡើងក្នុងគោលបំណងដូចពន្យល់អ៊ីចឹង។ ហើយគួរឲ្យភ្ញាក់ផ្អើល គេនិយាយថា "សមមិត្តនេះសំដៅទៅលើបញ្ហាជន គេមិនបានសរសេររៀបចំឡើងឲ្យបានច្បាស់លាស់ថា ជាអតីតបញ្ហាជននោះឡើយ។ វាគ្រាន់តែបង្ហាញថា យ៉ាងហោចណាស់នោះ គឺវាសំដៅទៅលើបច្ចុប្បន្នកាលតែប៉ុណ្ណោះ ហើយវាអាចមានការបកស្រាយ ឬផលប៉ះពាល់ទៅតាមបុគ្គលនីមួយៗ ក៏ប៉ុន្តែនេះជាអ្វីដែលខ្ញុំអានទៅវាយល់ដូច្នេះ។

**ស៖** អ៊ីចឹងដោយសារលោកយល់បែបហ្នឹងហើយ បានជាលោកសរសេរកថាខណ្ឌដែលខ្ញុំបានដកស្រង់អានជូនលោកអម្បាញ់មិញហ្នឹង អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ។ ជាការត្រឹមត្រូវចំណុចនេះ។

[១១:១៩:០៤]

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ គឺថាក្នុងសកម្មភាពរបស់លោកមុន ក្នុងអំឡុងពេល និងក្រោយពេលដែលលោកធ្វើការនៅតុលាការយើងនេះ ទោះបីជាធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា ឬក៏ការិយាល័យសហចៅក្រមស៊ើបអង្កេតក៏ដោយ ហើយនិងតាមរយៈការងារស្រាវជ្រាវរបស់លោកដើម្បីសរសេរអត្ថបទហ្នឹង តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើឈ្មោះហៅក្រៅរបស់លោក ឬក៏ឈ្មោះបដិវត្តន៍របស់លោក ខៀវ សំផន នោះគេហៅអ្វីដែរ?

**ឆ៖** ខ្ញុំតែងតែឮគេហៅគឺពីប្រភពផ្សេងៗ ឈ្មោះដែលប្រើប្រាស់ក្នុងឆ្នាំ៧៥ និង ៧៨ គេហៅឈ្មោះគាត់ថា ហែម។ ក៏ប៉ុន្តែមានរហស្សនាមថ្មីមួយទៀតសម្រាប់គាត់ៗ ហើយគេបានប្រើប្រាស់ក្រោយខែមករា ឆ្នាំ៧៩។ ខ្ញុំមិនចាំឈ្មោះថ្មីនោះទេ ក៏ប៉ុន្តែឈ្មោះរហស្សនាមថ្មីនោះគឺគាត់មាន ក៏ប៉ុន្តែវាមិនដូច ប៉ុល ពត ទេដែល ប៉ុល ពត ហ្នឹងគឺថាឈ្មោះគាត់ហ្នឹងហៅក្រៅរបស់គាត់នៅតែដដែលទេ

តែអ្នកក្រោយ អ្នកផ្សេងទៀតគឺថាក្រោយឆ្នាំ៧៩ ខែមករា ទៅមានឈ្មោះផ្សេងៗ។

**ស៖** អ៊ីចឹងបើចន្លោះពីឆ្នាំ៧៥ ដល់៧៩ ហ្នឹងគឺថាឈ្មោះហៅក្រៅ ឬឈ្មោះបដិវត្តន៍របស់គាត់ហ្នឹង ហែម អ៊ីចឹងទេ?

**ឆ៖** ត្រឹមត្រូវហើយ។ សំណួរនេះគឺថាមិនបានបញ្ជាក់ដោយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ផងដែរ។ ឈ្មោះដែលគេគាត់ប្រើប្រាស់ផ្សេង ឬហៅផ្សេងនោះ ខ្ញុំមិនដែលធ្លាប់ឮពីមុន ឬក៏ឮនៅកន្លែងណាដែលធ្លាប់ឮនោះឡើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណដែលបានឆ្លើយបញ្ជាក់ទាំងអស់នេះ ហើយនិងការអត់ធ្មត់របស់លោកក្នុងការឆ្លើយសំណួរមកខ្ញុំ ហើយសូមអរគុណលោកប្រធាន។ ខ្ញុំចប់ត្រឹមនេះហើយ។

[១១:២១:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ អរគុណលោក ស៊ីវ។ លោក ស៊ីវ ហេងឌ័រ ការស្តាប់សក្ខីកម្មរបស់លោករហូតមកដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ អង្គជំនុំជម្រះសូមអរគុណចំពោះលោក ស៊ីវ ហេងឌ័រ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលជាច្រើនថ្ងៃកន្លងមកនេះ ដោយភាពអត់ធ្មត់ ខិតខំអស់ពីសមត្ថភាព និងលទ្ធភាពរបស់ខ្លួន។

សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ អង្គជំនុំជម្រះសូមជូនពរលោក មានសុខភាពល្អ ជួបតែសំណាងល្អ ហើយទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ស៊ីវ ហេងឌ័រ វិលត្រឡប់ទៅកាន់ទីកន្លែងដែលជាគោលដៅដែលគាត់មានបំណងចង់ទៅ ឬក៏ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ។ ហើយលោក ស៊ីវ ហេងឌ័រ អាចចាកចេញពីបន្ទប់សវនាការនេះបានហើយ។

*(សាក្សីចេញពីបន្ទប់សវនាការ)*

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីឆ្លើយតបទៅនឹងកាសែតភ្នំពេញប៉ុស្តិ៍ដែលលោកតំណាងសហព្រះរាជអាជ្ញាបានស្នើសុំមកអង្គជំនុំជម្រះតាម

រយៈអ៊ីម៉ែល។សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ដូចប្រធានបានបញ្ជាក់គឺខ្ញុំបានស្នើពីលើកឡើងពីមុននេះ។ យើងខ្ញុំបានបញ្ជូនលិខិតទៅខាងនិពន្ធនាយក គឺថាយើងខ្ញុំបានបញ្ជូនលិខិតដែលជាលិខិតដែលធ្វើឡើងដោយនិពន្ធនាយកភ្នំពេញប៉ុស្តិ៍ហ្នឹងឲ្យអង្គជំនុំជម្រះ និងភាគីបានជ្រាប។ គឺនៅព្រឹកមិញនេះបានចុះផ្សាយនៅក្នុងភ្នំពេញប៉ុស្តិ៍ គឺថ្ងៃទី១៨ ខែកក្កដា ត្រង់ទំព័រ១៦ គឺបានន័យ -- គេលើកឡើងថា ខៀវ សំផន ត្រូវបានបង្ខំឲ្យនៅស្ងៀម។

[១១:២៣:៥៧]

ហើយនៅក្នុងនេះគឺមានសរសេរឈ្មោះ វ៉េកគែន, អង់តា ហ្គីសសេ, និង លោក សំអុន ដែលមានឈ្មោះនៅក្នុងនេះ។ អ្វីដែលខ្ញុំលើកឡើងនេះ គឺដោយសារតែយើងកំពុងតែមកដល់ដំណាក់កាលបញ្ចប់ការពិភាក្សាទៅលើ -- បញ្ចប់ទៅលើភស្តុតាងរួចមកហើយ ហើយក៏ប៉ុន្តែនៅពេលដែលនេះបែជាមានការចោទប្រកាន់ក្នុងៗជាសាធារណៈទៅលើបញ្ហានេះ។ ចំពោះខ្ញុំៗយល់ឃើញថា យើងមិនអាចអត់ទ្រាំចំពោះចំណុចនេះទេនៅក្នុងតុលាការ ក៏ប៉ុន្តែវាជាបញ្ហាដែលយើងត្រូវដោះស្រាយស្របទៅតាមច្បាប់ និងបទដ្ឋាន និងក្របខ័ណ្ឌសីលធម៌ផងដែរ។

នៅក្នុងនេះគឺមានការចោទប្រកាន់ច្រើន ក៏ប៉ុន្តែខ្ញុំនឹងលើកឡើងចំពោះចំណុចនៅក្នុងនេះមួយម្តងៗ។ ហើយឲ្យអង្គជំនុំជម្រះពិចារណា ប្រសិនចង់ស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនោះ គឺថាយើងខ្ញុំអាចធ្វើបាន។ ហើយក្នុងនេះ គឺយើងត្រូវគិត ត្រូវអនុវត្តវិធាន៣៥ ដែលជាការ -- ត្រូវព្រមានទៅកាន់មេធាវីការពារក្តីត្រង់ដែលថាលើកឡើងចំណុចនេះ ហើយគាត់អ្នកជ្រៀតជ្រែកកិច្ចការតុលាការ។ ហើយក្របខ័ណ្ឌសីលធម៌ការងាររបស់គាត់គឺស្ថិតនៅក្រោមក្របខ័ណ្ឌសីលធម៌ដែលវាតម្រូវឲ្យមេធាវីការពារក្តីគោរពតាមនៅក្នុងតុលាការនេះ។

ខ្ញុំនឹងលើកឡើងចំពោះការចោទប្រកាន់នេះមួយម្តងៗ ហើយខ្ញុំជឿថា ក្នុងនាមសហព្រះរាជអាជ្ញា យើងត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់នៅក្នុងកំណត់ហេតុ នៅក្នុងឱកាសឲ្យបានលឿនបំផុត។

[១១:២៥:៤៨]

ការចោទប្រកាន់ទី១ ដែលលើកឡើងនៅក្នុងលិខិតនេះ គឺលោក លោកស្រីចៅក្រម បានស្តាប់សាក្សីជាច្រើន ហើយទទួលយកភស្តុតាងឯកសាររាប់ពាន់ឯកសារ ក៏ប៉ុន្តែបានច្រានចោលនូវការព្រួយ

បារម្ភនានា ដែលលោកលើកឡើងក្រុមមេធាវីការពារក្តី។ នេះគឺជាការលើកឡើងខុស ចំពោះអ្វីដែលបានកើតឡើងនៅក្នុងសវនាការនេះ។ រាល់ពេលទាំងអស់ មេធាវីការពារក្តីទទួលបានឱកាសក្នុងតទល់ជាមួយនឹងតំណាងសហព្រះរាជអាជ្ញា និងតទល់ទៅលើឯកសារភស្តុតាង និងឯកសានានា ហើយក៏មានឱកាសនូវដាក់ឯកសារសម្ភារៈរបស់ខ្លួនផងដែរ។ ពេលវេលាគ្រប់ទាំងអស់នោះ គឺថាពួកគាត់មានឱកាសទាំងអស់នេះ ដូចដែលយើងមានឱកាសដូចគ្នា។

សង្ខេបសរុបមកវិញ នៅក្នុងតុលាការនេះ យើងមានសាក្សីដែលគាត់ផ្តល់សក្ខីកម្មអំពីប្រភព និងភាពពាក់ព័ន្ធនៃភស្តុតាង គឺសាក្សីមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានស្តាប់ឮអំពីបញ្ហាឧបសម្ព័ន្ធទាំងឡាយដែលតំណាងសហព្រះរាជអាជ្ញាបានដាក់ជូន ហើយមេធាវីមានសិទ្ធិ មានឱកាសបានឆ្លើយតបទៅលើចំណុចទាំងអស់នេះហើយ។

[១១:២៧:០៣]

ចំពោះការចោទប្រកាន់ មានការព្រួយបារម្ភរបស់មេធាវីការពារក្តីត្រូវបានច្រានចោល គឺជាការលើកឡើងខុស។ ហើយគឺវាខុសពីអ្វីដែលគាត់បានធ្លាប់ធ្វើរួចមកហើយ ឆ្លើយតបទៅនឹងឧបសម្ព័ន្ធ ហើយរួមទាំងគាត់មានឱកាសឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សី រួមទាំងសេចក្តីសន្និដ្ឋាន ដូចគាត់លើកឡើងកាលពីម្សិលមិញ។ បានន័យថា គ្មានអ្នកណាម្នាក់ត្រូវបានរារាំងឱកាស ហើយមិនត្រូវបានអង្គជំនុំជម្រះពិចារណាទៅលើព្រួយបារម្ភទាំងអស់នោះទេ។ ក៏ប៉ុន្តែមានសេចក្តីសម្រេចនានា ដែលបានលើកឡើង ដែលមានមេធាវីការពារក្តីត្រូវបានអង្គជំនុំជម្រះធ្វើការរំឭក ហើយមេធាវីការពារក្តីក៏មានសិទ្ធិប្តឹងសាទុក្ខឡើងទៅលើផងដែរ។ ដូច្នេះបានន័យថា សេចក្តីសម្រេចដែលបានណែនាំនេះ មិនមែនថាជាការលើកឡើងថាមិនយល់ មិនពិចារណាទៅលើការព្រួយបារម្ភ ហើយច្រានចោលអ្វីដែលលើកឡើងនោះទេ។ ការលើកឡើងដូច្នេះ គឺមិនគោរពតាមក្របខ័ណ្ឌសីលធម៌។

ខ្ញុំសូមរំឭកមេធាវីការពារក្តីថា នៅក្នុងឱកាសជាច្រើន នៅពេលដែលយើងស្នើសុំឱ្យទទួលយកសម្ភារៈឯកសារថ្មីនោះ គឺយើងខ្ញុំត្រូវដាក់ជាលាយលក្ខណ៍អក្សរ ហើយដោយផ្ទាល់មាត់ផងដែរ ឬក៏ដោយផ្ទាល់។ អង្គជំនុំជម្រះពេលខ្លះ គឺច្រានចោលសំណើរបស់ខ្ញុំដាក់ឯកសារសម្ភារៈថ្មី ក្នុងនោះគឺឯកសារអង្គការលើកលែងទោសអន្តរជាតិ សារទូរលេខរបស់សហរដ្ឋអាមេរិកមុនឆ្នាំ១៩៧៥ និងសក្ខី-កម្មរបស់សាក្សី ដូចជាសាក្សី មាស មុត របស់សាក្សី--

[១១:២៨:៤០]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់ជួយបញ្ជាក់ឈ្មោះសាក្សីម្តងទៀតអម្បាញ់មិញ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូម គឺចម្លើយរបស់ មាស វឿន ដែលផ្តល់សក្ខីកម្មក្នុងខែតុលា រួចមកហើយ។

ការចោទប្រកាន់ទី២ គឺការបដិសេធដោយអង្គជំនុំជម្រះ ការចោទប្រកាន់ថាអង្គជំនុំជម្រះបដិសេធមិនឲ្យធ្វើការពិភាក្សាជាក់ស្តែងទៅលើភស្តុតាងជាច្រើនដែលបានទទួលយក។ គេឆ្ងល់នៅពេលដែលអានឃ្លាទាំងអស់ហ្នឹង ថាតើមេធាវីការពារក្តី ខៀវ សំផន នោះ បានធ្វើការងារស្របទៅតាមភាពជាក់ស្តែង ឬក៏យ៉ាងម៉េច។ នៅថ្ងៃ០៩ ខែកក្កដា ថ្មីៗនេះ គឺមេធាវីការពារក្តីបានស្នើសុំឱកាសធ្វើការបង្ហាញទៅលើឯកសារគន្លឹះ ហើយមេធាវីការពារក្តីគាត់មិនធ្វើការឆ្លើយតប។ នៅពេលនោះ គឺខ្ញុំគួរតែស្នើសុំអង្គជំនុំជម្រះពិចារណាពេលវេលាបន្ថែមសម្រាប់គាត់។ ហើយអង្គជំនុំជម្រះ ក៏បានផ្តល់ពេលវេលាបន្ថែម។ ចៅក្រមប្រធាន ចៅក្រម ឡាវែន៍ បានឆ្លើយតបទៅលោក វែកគែន ថាតើគាត់ចង់ធ្វើការឆ្លើយតបទៅលើឯកសារគន្លឹះ ហើយគាត់នឹងឆ្លៀតយកឱកាសដែលផ្តល់ដោយអង្គជំនុំជម្រះនេះ យកទៅមកឆ្លើយតបដែរឬទេ? ជាការឆ្លើយតបទៅនឹងឯកសារគន្លឹះ ដែលវាជាបញ្ហាឆ្លើយតបទៅនឹងអ្វីដែលតំណាងសហព្រះរាជអាជ្ញាបានដាក់។ ក៏ប៉ុន្តែមេធាវីការពារក្តីខាង ខៀវ សំផន គាត់បដិសេធឱកាសដែលផ្តល់ជូននេះ។ ហើយព្រឹកនេះ មេធាវីការពារក្តីគឺស្នើសុំឲ្យយើង -- ហើយគាត់លើកឡើងនៅក្នុងលិខិតនោះឲ្យសាធារណជនយល់ខុសថា អ្វីដែលបានកើតឡើងនៅក្នុងតុលាការ។

[១១:៣០:៣០]

មេធាវីការពារក្តី គឺថាគាត់ឲ្យសាធារណជនយល់ខុស ហើយគាត់ជាអ្នកខកខានមិនទទួលយកឱកាសក្នុងការឆ្លើយតប ទោះបីជាឱកាសនោះបានផ្តល់ឲ្យមេធាវីការពារក្តីពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅលើសេចក្តីសន្និដ្ឋានទៅលើឯកសារក៏ដោយ។ ការអះអាងនេះ គឺថាជាការអះអាងមួយដែលជាការខឹងទៅនឹងតុលាការនេះតែប៉ុណ្ណោះ ហើយធ្វើឲ្យយើងយល់ថាមិនសមស្រប។

ចំណុចទី៣ គឺពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ មេធាវីការពារក្តីនៅពេលនេះគឺថា គាត់លើកតែបញ្ហាដីកាបំបែកកិច្ចដំណើរការនីតិវិធី ហើយគឺគាត់ពីមុននោះគាត់បានឯកភាព។ នេះជាចំណុចដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងលិខិត។ សូមដកស្រង់៖ “នៅពេលដែលរារាំងមេធាវីការពារក្តីមិនពិភាក្សាភស្តុតាងដាក់នៅក្នុងតុលាការដំណាក់កាលទី១ គឺដែលវាពាក់ព័ន្ធទៅនឹងគោលនយោបាយ

ជម្មៀស អង្គជំនុំជម្រះគួរឲ្យភ្ញាក់ផ្អើលនោះប្រកាសថាអង្គជំនុំជម្រះនឹងធ្វើការវិនិច្ឆ័យនៅក្នុងដំណាក់កាលទី១ អំពីការទទួលខុសត្រូវរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងគោលនយោបាយឧក្រិដ្ឋទាំងអស់។ ហើយនៅក្នុងលើកឡើងបន្ថែមទៀតថា ការលើកឡើងនេះគឺថាជាការរារាំងការងាររបស់មេធាវីការពារក្ដី"។

ដើម្បីជាប្រតិចារឹកវិសាលភាពនៃការជំនុំជម្រះនេះគឺថាបានកំណត់នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងខែកញ្ញា ឆ្នាំ២០១១ រួចហើយ មេធាវីការពារក្ដី ខៀវ សំផន មិនបានចោទលើកឡើងអំពីបញ្ហានេះឡើយ ហើយមិនស្នើសុំឲ្យមានការពិចារណាឡើងវិញនោះទេ។ ក៏ប៉ុន្តែគាត់ជំទាស់ការប្ដឹងរបស់តំណាងសហព្រះរាជអាជ្ញា ដែលស្នើសុំឲ្យធ្វើការពិនិត្យទៅលើដីកានេះឡើងវិញ។

[១១:៣២:១៨]

ហើយនៅទីនេះខ្ញុំនឹងយោងទៅលើការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់ខ្ញុំ។ ដើម្បីជាប្រតិចារឹកឲ្យបានច្បាស់លាស់ នេះគឺជាជំហររបស់មេធាវីការពារក្ដីក្នុងដំណាក់កាលជំនុំជម្រះ។ នៅក្នុងការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខភ្លាមរបស់តំណាងសហព្រះរាជអាជ្ញាទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E163/5/1/9 ត្រង់កថាខណ្ឌ៣១។ មេធាវីការពារក្ដីបានបញ្ជាក់យ៉ាងច្បាស់ថា ពួកគាត់យ៉ាងច្បាស់អំពីវិសាលភាពនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី និងវិសាលភាពនៃការជំនុំជម្រះ។ សូមដកស្រង់៖ "ក៏ប៉ុន្តែទោះបីយ៉ាងនេះក្ដី អង្គជំនុំជម្រះមិនបានចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី ដើម្បីសង្ខេបដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ប៉ុន្តែបានពិនិត្យលម្អិតទៅលើធាតុដែលមាននៅក្នុងហ្នឹង។ ដូចដែលអង្គជំនុំជម្រះបានពន្យល់រួចមកហើយ បញ្ហានៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី គឺ (ខ្ញុំអានលេខ២) ដើម្បីធានាថាដំណាក់កាលជំនុំជម្រះទី១ គឺបានពិនិត្យឲ្យបានហ្មត់ចត់ទៅលើបញ្ហាមូលដ្ឋាន និងការចោទប្រកាន់ទៅលើជនជាប់ចោទទាំងអស់។ ចំណុចទី៣ គឺដើម្បីផ្ដល់ជាមូលដ្ឋានសម្រាប់ការពិនិត្យឲ្យបានលម្អិតទៅលើអង្គហេតុដែលនៅសល់ចោទប្រកាន់ -- ចំពោះអង្គហេតុដែលនៅសល់ចោទប្រកាន់ជនជាប់ចោទនោះ គឺថាអាចនឹងជំនុំជម្រះដំណាក់កាលក្រោយៗ"។

[១១:៣៣:៥១]

មេធាវីការពារក្ដីក្រោយមកតវ៉ាថា សេចក្ដីសម្រេចនេះគឺថាមានសំអាងហេតុ ហើយមេធាវីការពារក្ដីគាត់យល់ហើយ។ នៅក្នុងកថាខណ្ឌ៤១ មេធាវីការពារក្ដីគឺមិនឯកភាពជាមួយនឹងទឡ្ហីករណ៍ថា អង្គជំនុំជម្រះខកខានមិនបានផ្ដល់ហេតុផលសមស្របនោះទេ។ កថាខណ្ឌ៤៩ ប្រយោគទី២ ជាក់ស្ដែងនោះគឺថា "ផ្ទុយទៅនឹងការអះអាងរបស់តំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងបាន

ផ្តល់សំអាងហេតុគ្រប់គ្រាន់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដោយពិចារណាអំពីហានិភ័យដែលអាចក្នុងការពន្យារវិសាលភាពសំណុំរឿង០០២ -- សំណុំរឿងដំណាក់កាល០០២"។ ក៏ប៉ុន្តែគឺការលើកឡើងដូច្នេះគឺមិនសមស្រប ហើយមេធាវីការពារក្តីមិនបានលើកឡើងបញ្ហាណាមួយពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះនោះទេ ក៏ប៉ុន្តែបែរជាបានជំទាស់ទៅនឹងបណ្តឹងសាទុក្ខរបស់តំណាងសហព្រះរាជអាជ្ញា។ ហើយក៏ប៉ុន្តែនៅពេលនេះគឺលើកឡើងថាវាជាការភ័ន្តច្រឡំ និងធ្វើឲ្យគាត់មានការយល់ច្រឡំទៅលើបញ្ហានេះ ហើយជាការរារាំងចំពោះការលើកឡើងរបស់មេធាវីការពារក្តី។

[១១:៣៥:០៧]

ការចោទប្រកាន់បន្ថែម: គឺចំណុចទី៤ នៅក្នុងលិខិត "អង្គជំនុំជម្រះមិនដែលចាប់អារម្មណ៍ក្នុងការស្តាប់នូវការលើកឡើងរបស់មេធាវីការពារក្តីនោះទេ។ ចំណុចនេះ គឺជាការលើកឡើងអះអាងខុសតែម្តង"។ ខ្ញុំសូមលើកឡើងទិដ្ឋភាពមួយចំនួននៅក្នុងការជំនុំជម្រះនេះ ដើម្បីឲ្យយើងបានយល់ទាំងអស់គ្នា។ មេធាវីការពារក្តីទទួលបានពេលវេលាស្មើគ្នាក្នុងការសួរទៅកាន់សាក្សី ពួកគាត់មានឱកាសក្នុងការស្នើសុំសាក្សីរបស់ពួកគាត់។ ពួកគាត់បានស្នើសុំ ហើយអង្គជំនុំជម្រះបានកោះហៅសាក្សីទាំងអស់នោះ។ ពួកគាត់មានឱកាសធ្វើការបង្ហាញឯកសារ ក៏ប៉ុន្តែបែរជាបដិសេធមិនធ្វើការឆ្លើយតបទៅនឹងការបង្ហាញឯកសារ។

ដូច្នេះ ជាការពិតទៅ គឺថាមេធាវីការពារក្តី គឺមិនបានធ្វើការតវ៉ាអំពីចំណុចសារធាតុនៅក្នុងការជំនុំជម្រះនោះទេ លើកលែងមកដល់ដំណាក់កាលក្រោយនេះទើបគាត់លើកឡើង។ វាមានសារៈសំខាន់ណាស់ យើងដឹងហើយថានៅថ្ងៃ២៧ ខែឧសភា -- គឺដើម្បីប្រតិចារឹកតុលាការនេះ នៅថ្ងៃនោះ ខៀវ សំផន បានបញ្ជាក់ថាគាត់បន្តផ្តល់ចម្លើយថ្មីៗ នៅថ្ងៃទី២៧ ខែឧសភា នោះ គឺនៅពេលដែលគាត់បានបញ្ជាក់នោះ គាត់មិនបានលើកឡើងអំពីបញ្ហានៃការជំនុំជម្រះដោយយុត្តិធម៌ ហើយមិនលើកឡើងអំពីឱកាសដែលគាត់មិនទទួលបាននូវការដាក់នៅសេចក្តីសន្និដ្ឋាន ឬឯកសាររបស់ខ្លួននោះទេ។ ក៏ប៉ុន្តែចំណុចនេះគឺគាត់បានលើកឡើងទាញ ហើយលើកឡើងជាការបង្ហាញខុសឲ្យយើងយល់ទៅវិញនៅពេលនេះដើម្បីដាក់បញ្ចូលនៅប្រតិចារឹក។

[១១:៣៦:៤៧]

ចំណុចលើកឡើងខុសមួយទៀត នៅក្នុងលិខិតចំហនេះ គឺពាក់ព័ន្ធទៅនឹងកាលៈទេសៈដែលនាំទៅដល់ -- ដែលធ្វើឲ្យលោក ខៀវ សំផន បដិសេធមិនផ្តល់សក្ខីកម្មឆ្លើយតបទៅនឹងសំណួរ។ ការចោទ

ប្រកាន់នៅក្នុងនេះ គឺអង្គជំនុំជម្រះបានបដិសេធសំណើសុំរបស់ ខៀវ សំផន ទាំងអស់ ជាពិសេសពាក់ព័ន្ធទៅនឹងទម្រង់នៃការពិនិត្យសាកសួរទាំងអស់នេះ។ មិនពិតទេ អង្គជំនុំជម្រះពីដំបូងបានទទួលសំណើសុំមួយចំនួន ក៏ប៉ុន្តែបដិសេធសំណើសុំខ្លះនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំលើកឡើងថា វាជាសេចក្តីសម្រេចមួយសមស្រប ហើយវាស្របទៅនឹងកាសម្រេចទៅលើរឿងក្តីនៅក្នុងតុលាការអន្តរជាតិនានា។ ក៏ប៉ុន្តែនៅពេលដែលធ្វើការសម្របសម្រួលនេះ ហើយនៅពេលដែលស្តាប់ការបដិសេធរបស់ ខៀវ សំផន មិនឆ្លើយតប មិនផ្តល់សក្ខីកម្ម អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យយើងខ្ញុំផ្តល់ជាអនុសាសន៍បន្ថែមសម្រាប់អង្គជំនុំជម្រះ។

ផ្ទុយទៅនឹងមាត្រាទាំងអស់នេះ ការសម្របសម្រួលនេះ វាមិនមែនថាវាផ្តល់ពេលវេលាបន្ថែមឲ្យគាត់ត្រៀមខ្លួនសម្រាប់ឆ្លើយតបនោះទេ យើងខ្ញុំបានផ្តល់បញ្ជីនូវប្រធានបទសំណួរដែលគាត់នឹងឆ្លើយ ហើយឯកសារសម្ភារៈទាំងអស់នេះ គឺថាខ្ញុំមិនបានលាតត្រដាងទៅដល់សាធារណជនដើម្បីជាការរំលោភបំពានទៅលើសិទ្ធិគាត់នោះទេ។ ខ្ញុំមិនបានធ្វើដូច្នេះឡើយ។

[១១:៣៨:៣២]

បាទ ខ្ញុំឈានដល់សេចក្តីសន្និដ្ឋានបញ្ចប់ហើយ។ យើងខ្ញុំសូមស្នើដោយគោរពថា ការនិយាយមិនពិត និងការនាំឲ្យយល់ខុសទៅលើកិច្ចដំណើរការនីតិវិធីបន្តទៅមុខទៀតនៅចំពោះមុខអង្គជំនុំជម្រះនេះ មេធាវីការពារក្តីមានចេតនាយ៉ាងច្បាស់ក្រឡែតក្នុងការជ្រៀតជ្រែកចូលដល់ការចាត់ចែងកិច្ចដំណើរការនីតិវិធីកិច្ចការយុត្តិធម៌ ដែលប្រការនេះ គឺថាវាស្ថិតនៅក្នុងឆ្ងាយពីបទដ្ឋានវិជ្ជាជីវៈ ប្រកបទៅដោយឯកសារវាជ្យភាព។ ខ្ញុំសូមយោងទៅឯកសារមួយទាក់ទងទៅនឹងគោលបំណងនេះ គឺសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ និយាយអំពីគោលការណ៍ជាមូលដ្ឋាន ដែលជាឯកសាររបស់អង្គការសហប្រជាជាតិអនុវត្តចំពោះគ្រប់ភាគីទាំងអស់នៅក្នុងបន្ទប់សវនាការនេះ។

ឯកសារនេះ គឺ អ.ស.ប 8/CONF.144.28/REV.1 ខ្ញុំគិតឃើញថា ភាគីនិមួយៗគួរណាស់តែអាននូវឯកសាររបស់អង្គការសហប្រជាជាតិនេះ។ យើងខ្ញុំគ្រាន់តែរំឭកដល់ភាគីទាំងអស់ថាត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួន។ មាត្រា១២ សូមដកស្រង់៖ "មេធាវីគ្រប់ពេលទាំងអស់ត្រូវតែរក្សានូវសេចក្តីស្មោះត្រង់ ហើយនិងសុចរិតភាពនៃវិជ្ជាជីវៈរបស់ខ្លួន និងចូលរួមក្នុងការចាត់ចែតរដ្ឋបាលតុលាការ។ មាត្រា១៤: ក្នុងការការពារដល់កូនក្តីរបស់ខ្លួន មេធាវីត្រូវតែបំពេញការងារដោយឧស្សាហ៍ព្យាយាមគ្រប់ពេលវេលា និងទទួលស្គាល់នូវក្រមសីលធម៌វិជ្ជាជីវៈដោយអនុវត្តអនុលោមទៅតាម២៣ ដែលថា

ក្រមវិជ្ជាជីវៈត្រូវអនុវត្តនៅពេលដែលមេធាវីការពារក្តីចូលរួមនៅក្នុងកិច្ចការសាធារណៈ ដូចជាការពិភាក្សាអំពីការចាត់ចែងរដ្ឋបាលយុត្តិធម៌ជាដើម។

[១១:៤១:00]

លោក លោកស្រី ជាទីគោរព! មាត្រានេះគឺបង្ហាញអំពីការបង្ហាញនូវអង្គហេតុដែលមិនពិត ដែលជាការធ្វើឲ្យសាធារណជនយល់ខុស ដូចយើងខ្ញុំបានជម្រាបហើយ ធ្វើឲ្យកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះធ្លាក់ទៅក្នុងការប្រទូសរ៉ាយជាមួយនឹងគ្នា។ ជាពិសេស បញ្ហាដែលស្ថិតនៅក្រោមការពិចារណារបស់អង្គជំនុំជម្រះនោះ។ ជាការពិត នេះជាការខកខានក្នុងការបំពេញការងារប្រកបទៅដោយឯករាជ្យ និងវិជ្ជាជីវៈ ដែលសារនេះគឺថាគួរតែបង្ហាញឲ្យបានខ្លះតាមរយៈតុលាការនេះ។

យើងយោងតាមវិធាន៣៥ ស្នើសុំឲ្យអង្គជំនុំជម្រះចេញសេចក្តីព្រមានដល់មេធាវី គង់ សំអុន និង អង់តា ហ្គីសសេ និង មេធាវី វ៉េកគែន ទៅដល់មេធាវីសាមី គណៈមេធាវីរបស់មេធាវីមួយរូបៗ ហើយតាមរយៈអង្គភាពគាំពារ ការការពារក្តីនៃសាលាក្តីនេះ ហើយដែលស្នើសុំឲ្យការស្តីបន្ទោស ហើយ និងចេញឯកសារនេះជាសាធារណៈ។ ចំពោះការបង្ហាញនូវអ្វីមួយដែលនាំឲ្យមានការខឹងសម្បាពីសំណាក់សាធារណជននោះ។

ប្រសិនជាលោក លោកស្រីចៅក្រមមានសំណួរអី យើងខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីឆ្លើយតបទៅនឹងបណ្តារសំណួរទាំងឡាយ។

[១១:៤២:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធានដែលអនុញ្ញាតឲ្យខ្ញុំនិយាយពីរបីនាទី។ ខ្ញុំសូមឆ្លើយតបទៅនឹងការបោះពុម្ពកាសែតហ្នឹង ដែលធ្ងន់ធ្ងរណាស់។ ដោយនិយាយឲ្យច្បាស់តែម្តង គឺជាការនិយាយខុស ហើយ និងមិនស្មោះត្រង់ទាល់តែសោះ។

ខ្ញុំសូមធ្វើការកត់សម្គាល់ជាបឋម ជាដំបូងគឺនៅពេលដែលយើងមិនចង់និយាយទេ វាជាការងាយស្រួលណាស់ក្នុងនិយាយយកឲ្យត្រូវខ្លួនឯង ថាគេបង្ខំមិនឲ្យនិយាយ ហើយគេមានគេរាំងស្ទះ។

អ៊ីចឹងនៅករណីខាងការពារក្ដី គឺនិយាយយ៉ាងដូច្នេះឯង។

ការកត់សម្គាល់ទី២ គឺថាខ្ញុំសោកស្ដាយណាស់នៅក្នុងការជ្រើសរើសផ្លូវដើរបែបនេះ គឺថាក្នុងការនិយាយយ៉ាងដូច្នេះ។ នៅសវនាការយើងនេះ យើងធ្លាប់និយាយអំពីបញ្ហានេះហើយ ជាច្រើននាទី ដោយសារតែអង្គជំនុំជម្រះគិតថាពួកខាងការពារក្ដីនេះមិន -- ធ្វើមិនត្រូវ ក៏គេបកទៅនិយាយជាមួយអ្នកកាសែតវិញ។ អ៊ីចឹងខ្ញុំគិតថា កន្លែងអី -- នៅកន្លែងយើងនេះជាកន្លែងនិយាយតទល់គ្នាយ៉ាងស្រួល។ ជាកន្លែងដែលយើងមិនបាច់ថានិយាយយកត្រូវខ្លួនឯងគ្រប់ចំណុចនោះទេ ហើយក៏វាជាកន្លែងយើងអាច ឬក៏យើងអាចថាបំភ្លៃបំភ្លើសរឿងដែលកើតឡើងជាដើម។

[១១:៤៤:៣២]

ខ្ញុំគិតថា អត្ថបទកាសែតនេះគឺជាការប្រមាថមើលងាយអង្គជំនុំជម្រះ ហើយជាការប្រមាថមើលងាយទៅដល់កិច្ចសវនាការអស់រយៈពេលជាង២ឆ្នាំមកផង ហើយក៏វាជាការប្រមាថមើលងាយដល់ដើមបណ្ដឹងរដ្ឋប្បវេណីដែលយើងការពារដល់ប្រជាជនកម្ពុជា។ ខ្ញុំសូមគាំទ្រទាំងស្រុងដល់អំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា ការចោទប្រកាន់របស់ក្រុម ខៀវ សំផន ទាំងប៉ុន្មាននេះមិនត្រឹមត្រូវ គឺថាការចោទប្រកាន់ទាំងអស់នេះ មិនត្រឹមត្រូវទាល់តែសោះ។ មិនមានមូលដ្ឋាន ហើយត្រូវបានលើកឡើងនៅទីនេះហើយ ហើយត្រូវបានបដិសេធដោយតុលាការយើងផងដែរ។

ខ្ញុំគ្រាន់តែចង់ធ្វើការកត់សម្គាល់ពីរទាក់ទងនឹងចោទប្រកាន់ពីរជាក់លាក់។ ទាក់ទងនឹងបរិមាណឯកសារដែលច្រើន។ ខ្ញុំសួរទៅខាងការពារក្ដីលោក ខៀវ សំផន ថាតើពេលមកចូលក្នុងការជម្រះសេចក្ដីនេះ តើក្នុងឋានៈជាមេធាវីស៊ីវិលឡនោះ មានភ្ញាក់ផ្អើលពីវត្តមាន ឬក៏ចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ខ្ញុំសង្ឃឹមថាគាត់មិនភ្ញាក់ផ្អើលទេ។

[១១:៤៥:៥៧]

តើគាត់ភ្ញាក់ផ្អើលនឹងចំនួនឯកសារច្រើនទេ? ចំពោះខ្ញុំប្រហែលថាការដែលមានឯកសារនេះ គឺវាបង្ហាញពីភាពយុត្តិធម៌ ភាពមិនលម្អៀងវិញទេ។ អ៊ីចឹងបើផ្ទុយទៅវិញ បើសិនជាលោក ខៀវ សំផន ហើយលោក នួន ជា នោះត្រូវបានគេកាត់ទោស កាត់សេចក្ដីដោយមានឯកសារពីរបីនោះ អានេះមិនត្រឹមត្រូវទេ។ វាអាចមានភាពលម្អៀង។

ការសម្គាល់ទី២ គឺទាក់ទងនឹងគោលនយោបាយទាំងប្រាំ។ ខ្ញុំបានអាននៅក្នុងអត្ថបទកាសែតហ្នឹងមានសរសេរថា៖ “អង្គជំនុំជម្រះហ្នឹងត្រូវបានបញ្ចូលនៅពេលដំណាក់កាលចុងក្រោយនៃការជម្រះ

សេចក្ដីហ្នឹង គឺថាគោលនយោបាយទាំងប្រាំហ្នឹងយកមកជជែកវែកញែក"។ គឺខុសហើយ ព្រោះថានៅក្នុងដីកាបំបែកសំណុំរឿងនីតិវិធី គឺថាមានកថាខណ្ឌដែលសរសេរថែងអំពីគោលនយោបាយទាំងប្រាំ ហើយជាច្រើនដងនៅក្នុងសវនាការនេះ ចៅក្រមបានសង្កត់ធ្ងន់ឲ្យនិយាយអំពីគោលនយោបាយទាំងប្រាំហ្នឹង។ អ៊ីចឹងគឺថាការអះអាងរបស់មេធាវី ខៀវ សំផន ខុស ការចោទប្រកាន់នេះខុស។ អ្វីដែលមេធាវីលោក ខៀវ សំផន ធ្វើនៅពេលនេះ គឺគ្រាន់តែជាការប៉ុនប៉ងដកខ្លួនចេញពីជម្រះសេចក្ដី ឬក៏ការបំបាត់ភាពជឿកជាក់បានរបស់តុលាការ ហើយនិងគ្រាន់តែជាយុត្តិសាស្ត្រមួយតែប៉ុណ្ណោះ។

[១១:៤៧:៣៧]

ការពិតទៅ បើខ្ញុំចង់រំឭកគឺថា ចាប់តាំងពីដំបូងនៃការជម្រះសេចក្ដីនេះ ខ្ញុំសូមរំឭកថា ខៀវ សំផន ហើយនិង នួន ជា នោះ សន្យាជាច្រើនដង ហើយនិងការពន្យល់ជាច្រើនដង ឧទាហរណ៍ដូចជាលោក ខៀវ សំផន គាត់និយាយប្រាប់ជាច្រើនដង ថាគាត់នឹងនិយាយនៅពេលចុងសវនាការ។ ហើយគាត់បានសន្យាទៅតុលាការ ទៅប្រជាជនកម្ពុជា ទៅភាគី។ កាលណោះ គាត់និយាយយ៉ាងដូច្នេះ។ គាត់និយាយថាគាត់នឹងនិយាយនៅចុងសវនាការ។ ហើយជាច្រើនដង គាត់ថាគាត់នឹងនិយាយនៅចុងក្រោយហ្នឹងឯង។

ខ្ញុំយល់ឃើញថា -- ខ្ញុំជិតចប់ហើយលោកប្រធាន -- ខ្ញុំគិតថា ការជម្រះសេចក្ដីមិនមែនជាសំណួរសំណុំសំណួរច្រើន ហើយវាអរូបិយនោះទេ ត្រូវតែមាន យើងសុទ្ធតែជាអ្នកច្បាប់ អ្នកអាជីព។ គឺយើងអ្វីដែលយើងនិយាយនេះ គឺថាយើងនិយាយទៅកាន់ប្រជាជន ទៅកាន់សង្គមមួយទាំងមូល ទៅកាន់សហគមន៍អន្តរជាតិ ទៅជនរងគ្រោះ ទៅដើមបណ្ដឹងរដ្ឋប្បវេណី ដែលតំណាងឲ្យជនរងគ្រោះទាំងអស់តែម្ដង។ ខ្ញុំគិតថាការជួបគ្នា ការប្រឈមមុខគ្នានេះ គឺថា ខៀវ សំផន, នួន ជា គាត់បដិសេធចោលហើយជាជម្រើសរបស់គាត់ ក៏ប៉ុន្តែខ្ញុំយល់ឃើញថា មិនមែនជាស្មោះត្រង់នោះទេនៅក្នុងការជ្រើសរើសបែបនេះ ពីព្រោះថាគាត់កំពុងតែចង់ឲ្យអង្គជំនុំជម្រះទទួលខុសត្រូវជំនួសវិញ ឬក៏អ្នកផ្សេងទៀតក៏បានដែរ ក៏ប៉ុន្តែគាត់មិនចង់ទទួលខុសត្រូវខ្លួនឯងទេ។

[១១:៤៩:៣២]

ខ្ញុំពុំមានសំណើអីទាក់ទងទៅនឹងការដាក់ទណ្ឌកម្មនោះទេ អានេះអាស្រ័យទៅលើអង្គជំនុំជម្រះ ក៏ប៉ុន្តែខ្ញុំចង់គូសបញ្ជាក់ថា ភាពធ្ងន់ធ្ងរនៃអត្ថបទកាសែតនេះ ដែលបន្តិចម្ដងៗនៅសប្ដាហ៍ប៉ុន្មានសប្ដាហ៍ចុងក្រោយនេះ ប៉ុន្មានថ្ងៃចុងក្រោយនេះ ខ្ញុំគិតថា ការចោទប្រកាន់ប្រឆាំងទៅលើអង្គជំនុំជម្រះនេះ គឺជា

ការប្រមាថមើលងាយអង្គជំនុំជម្រះ ប្រមាថមើលងាយដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសាធារណជនដែលមកទីនេះដើម្បីស្តាប់ថាមានរឿងអ្វីកើតឡើងគេនិយាយអំពីអ្វី។ អ៊ីចឹងខ្ញុំសូមសង្កត់ធ្ងន់លើចំណុចចុងក្រោយនេះ គឺថាជាការធ្ងន់ធ្ងរមែនទែនអត្ថបទកាសែតនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ខ្ញុំមានមតិបន្ថែមបន្តួចទៅលើអ្វីដែលខាងតំណាងសហព្រះរាជអាជ្ញា ហើយនិងសហការីរបស់ខ្ញុំបានលើក។ ក៏ប៉ុន្តែមិនផ្តោតជាសំខាន់ទៅលើផ្នែកទិដ្ឋភាពច្បាប់ទេ។

[១១:៥០:៣០]

ដើមបណ្តឹងរដ្ឋប្បវេណី -- មតិរបស់យើងខ្ញុំគឺសំដៅទៅលើអ្វីដែលជាការចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះជនជាប់ចោទ។ នៅក្នុងដំណាក់កាលដំបូងនៃរឿងក្តីនេះ ជាពិសេសនៅក្នុងដំណាក់កាលស៊ើបអង្កេត ជនជាប់ចោទមិនបាននិយាយ ឬក៏ឆ្លើយទៅនឹងសំណួរនានារបស់សហចៅក្រមស៊ើបអង្កេតទេ។ ហើយព័ត៌មានទាំងអស់នេះបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានការងឿងឆ្ងល់ ហើយមានការខកចិត្តជាច្រើនចំពោះការមិនឆ្លើយនេះ។ ក៏ប៉ុន្តែនៅពេលដែលចាប់ផ្តើមសវនាការដោយអង្គជំនុំជម្រះសាលាដំបូងនេះ ជនជាប់ចោទដែលមានលោក នួន ជា និងលោក ខៀវ សំផន ជាពិសេសបានចាប់ផ្តើមឆ្លើយទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ដែលធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីយល់ថាជនជាប់ចូលរួមនៅក្នុងការបង្ហាញការពិត។ ក៏ប៉ុន្តែការសង្ឃឹមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ក៏ត្រូវបាត់មកវិញនៅពេលដែលមេធាវីជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីតែងតែសួររហូតថាហេតុអ្វីក៏ជនជាប់ចោទមិនឆ្លើយ? ថាតើយើងរកយុត្តិធម៌យ៉ាងដូចម្តេចប្រសិនបើជនជាប់ចោទមិនឆ្លើយ? យើងកាត់ក្តីយ៉ាងដូចម្តេច?

នេះគឺជាសំណួរដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវឆ្លើយយ៉ាងពិបាកចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលជាអ្នកដែលខ្លួនតំណាងឲ្យ។

[១១:៥២:៣៧]

ទន្ទឹមនឹងពេលដែលលោក អៀង សារី បានទទួលមរណភាពនៅខែ៣នេះ ដើមបណ្តឹងរដ្ឋប្បវេណី

ក៏បានធ្វើការមួយចំនួន បានស្នើសុំតាមរយៈជាសេចក្តីថ្លែងការណ៍សាធារណៈ សូមឲ្យជនជាប់ចោទនិយាយហើយលើក -- និយាយអំពីតម្លៃនៃការឆ្លើយ ឬក៏ការបំភ្លឺរបស់ជនជាប់ចោទ ថាវាមានតម្លៃយ៉ាងណាចំពោះពួកគាត់ ក៏ដូចជាសង្គមជាតិ ប្រសិនបើគាត់ឆ្លើយទៅនឹងសំណួរនានា។

នៅពេលនេះដើមបណ្តឹងរដ្ឋប្បវេណី -- យើងមិនបានជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីច្រើនទេ ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចមានការខកចិត្តខ្លាំងមែនទែន ប្រសិនបើជនជាប់ចោទមិនឆ្លើយ។ ហើយខ្ញុំគ្មានអ្វីបន្ថែមច្រើនទេ គ្រាន់ថាក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីយើងខ្ញុំនៅតែសំណូមពរឲ្យជនជាប់ចោទចូលរួមនៅក្នុងការឆ្លើយ។ ជាពិសេសសម្រាប់ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាជនរងគ្រោះ ហើយនិងមនុស្សជំនាន់ក្រោយថែមទៀត ដើម្បីឲ្យដឹងថាតើមានអ្វីកើតឡើងនៅក្នុងសម័យខ្មែរក្រហមនោះ ដែលធ្វើឲ្យមានជនរងគ្រោះមានច្រើនយ៉ាងដូច្នេះ។

ខ្ញុំអស់យោបល់ហើយ សូមអរគុណលោកប្រធាន។

[១១:៥៣:៥៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៤:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ នាពេលនេះសវនាការស្តាប់សក្ខីកម្មសាក្សីបានបញ្ចប់ហើយ ហើយដំណើរការស្តាប់នូវសេចក្តីតបរបស់ភាគីតំណាងសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការចុះផ្សាយនូវសារព័ត៌មានភ្នំពេញប៉ុស្តិ៍ក៏បានចប់ហើយដែរ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៥:៤៦]

ខាងក្រុមមេធាវីការពារក្តី ខៀវ សំផន តើមានមតិយោបល់អ្វី ចង់មានមតិយោបល់អ្វីដែរទេ? អង្គជំនុំជម្រះកត់សម្គាល់មិនឃើញការស្នើសុំ បានជាអង្គជំនុំជម្រះមិនបានផ្តល់វេទិកាដូច្នេះ។

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ លោកប្រធានខ្ញុំពិតជាចង់ធ្វើការកត់សម្គាល់ដោយខ្លី។ ទី១ សូមឲ្យច្បាស់ទាំងអស់គ្នា ក្នុងឋានៈជាមេធាវីការពារក្តី យើងមិនដែលចង់ជេរប្រមាថអ្នកណាទេ។ យើងមិនចង់

ជេរប្រមាថអង្គជំនុំជម្រះ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ប្រជាជនកម្ពុជា សង្គមកម្ពុជាទេ។ នេះជាការកត់សម្គាល់ទី១។

ការកត់សម្គាល់ទី២ ក្នុងឋានៈជាមេធាវីការពារក្តី តួនាទីរបស់យើងតំណាងកូនក្តីរបស់យើង។ ក្នុងការធ្វើម៉េចជួយឲ្យគាត់បានដឹងអំពីអ្វីដែលបានកើតឡើង។ ហើយនៅក្នុងអត្ថបទដែលបានបោះពុម្ពផ្សាយដោយភ្នំពេញប៉ុស្តិ៍នោះ គឺវាមិនមានអ្វីដែលពាក់ព័ន្ធទៅនឹងទទ្បីករណ៍ -- គឺវាពាក់ព័ន្ធទៅនឹងទទ្បី-ករណ៍វាខុស -- វាមិនខុសពីអ្វីដែលយើងបានលើកឡើងនៅក្នុងតុលាការនេះទេ។ ខ្ញុំសូមយោងលើឯកសារ E3/200 -- E284 -- E288.4 គឺថាមានច្បាស់ណាស់ គឺថាសង្ខេបនៅក្នុងអត្ថបទហ្នឹងហើយ។ អ្វីដែលយើងលើកឡើងអំពីបញ្ហានៃការបំបែកនីតិវិធីនោះ យើងបាននិយាយរួចមកហើយនៅក្នុងពេលដែលយើងបានពិនិត្យភស្តុតាងនោះ។ ហើយខ្ញុំជាអ្នកធ្វើការជំទាស់ ហើយខ្ញុំក៏ជាអ្នកពន្យល់បញ្ហានៅពេលដែលមានសវនាការលើកឯកសារស្តីពីសហឧក្រិដ្ឋកម្មរួមនោះ។

[១១:៥៧:៤៩]

ខ្ញុំសូមចាប់ផ្តើមត្រង់ចំណុចនេះ នេះជាចំណុចសំខាន់។ ខ្ញុំគិតថាវាជារឿងអាស្រូវហើយដែលគេបន្ទោសយើងថា យើងមិនយល់ពីអ្វីដែលបានសម្រេចដោយអង្គជំនុំជម្រះថា យើងមិនធ្វើកាបណ្តឹងឧទ្ធរណ៍។ ចំពោះយើង យើងយល់ច្បាស់ណាស់អំពីទៅលើព័ត៌មានដែលយើងទទួលបានពីអង្គជំនុំជម្រះ។ ដូច្នេះ យើងគិតថាមិនមានការប្រែក្រឡាស់អីទេ យើងបានពន្យល់អស់ ច្បាស់អស់ហើយ យើងបាននិយាយយ៉ាងស៊ីជម្រៅទៅលើបញ្ហារបស់យើង ហើយគឺខ្ញុំហ្នឹងហើយជាអ្នកលើកឡើងខ្លួនឯងផ្ទាល់នៅក្នុងសវនាការ។ ខ្ញុំលើកឡើងយ៉ាងច្បាស់ គឺថានៅពេលដែលមានការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវដែលពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ហើយអ្វី -- តើអ្វីទៅដែលខ្ញុំបាននិយាយនៅក្នុងពេលនោះ នោះ? ពេលនោះ ខ្ញុំបាននិយាយ ចំពោះយើងជាមេធាវីការពារក្តី យើងយល់ យើងដឹងថា យើងយោងទៅលើឧបសម្ព័ន្ធ។ ខ្ញុំបានធ្វើនៅក្នុងសវនាការហើយ តែឥឡូវខ្ញុំលើកឡើងវិញម្តងទៀត គឺE124/7.3 ដែលឯកសារនេះបានពន្យល់ទៅដល់ភាគីទាំងអស់អំពីវិសាលភាពនៃការពិភាក្សាគ្នានៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១។

[១១:៥៩:០៧]

ដូច្នេះ ខ្ញុំសូមយោងទៅលើកថាខណ្ឌ៥ នៃឧបសម្ព័ន្ធនេះ ហើយកថាខណ្ឌ៥ នេះបានពន្យល់ថាអំពីការ -- អំពីវិសាលភាពនៃសំណុំរឿង០០២/០១ ដែលនិយាយអំពី៖

ក) គឺការទទួលខុសត្រូវដែលកើតចេញអំពីការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ដែលមាននៅក្នុងការខណ្ឌ១៥២១-២៥ លើកលែងតែងការរំលោភធ្ងន់ធ្ងរទៅលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ហើយនិងនិយាយលម្អិតទៅលើការបង្កើតសហករណ៍ ការអប់រំសមាសភាពមិនល្អ ការកម្ទេចខ្មាំងទាំងក្នុង និងក្រៅបក្ស ហើយនិងការកំណត់ទៅលើការរៀបអាពាហ៍ពិពាហ៍។ គឺយើងគិតអំពីទាហាននៃសាធារណរដ្ឋខ្មែរ។

ចំពោះកថាខណ្ឌដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះក្រុមជាក់លាក់មួយចំនួន ឧទាហរណ៍ដូចជាក្រុមជនជាតិចាម វៀតណាម ពុទ្ធសាសនិក អ្នកទទួលខុសត្រូវ និងមន្ត្រីរបស់អតីតសាធារណរដ្ឋ។ ដោយផ្អែកទៅលើឧបសម្ព័ន្ធហ្នឹងហើយ យើងមិនមែនជាអ្នកបង្កើតដោយខ្លួនឯងទេ គឺឧបសម្ព័ន្ធហ្នឹងបានកើតឡើងនៅក្នុងអំឡុងពេលសេចក្តីសម្រេចទៅលើការបំបែកនីតិវិធី ដោយបង្ហាញអំពីវិសាលភាពដែលយើងត្រូវតែពិនិត្យមើល។

[១២:០០:៣០]

យើងបានពន្យល់នៅពេលសហសវនាការទៅលើសហឧក្រិដ្ឋកម្មរួម ដែលទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ ដែលថានៅក្នុងលក្ខខណ្ឌហ្នឹងហើយ ដែលគឺថានៅក្នុងឧបសម្ព័ន្ធហ្នឹងមិននិយាយអំពីគោលនយោបាយទាំងអស់ហ្នឹងទេ។ នេះជាចំណុចទី១ដែលបាន -- ដែលខ្ញុំពន្យល់ថាហេតុអ្វីបានជានៅពេលនោះមេធាវីការពារក្តីបានលើកឡើងអំពីបញ្ហា ហើយដោយវាបង្កឲ្យមានបញ្ហា។

ហើយបន្ទាប់មកទៀត សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីក៏បានពន្យល់ថាយើងមិនអាចនិយាយតែអំពីអត្ថិភាពទាំងអស់នោះទេ យើងត្រូវតែនិយាយអំពីការអនុវត្តផងដែរ។ ដូច្នេះ វាអាចបង្កើតទៅជាបញ្ហាច្បាប់សំខាន់។ នេះមិនមែនជារឿងថ្មីទេ យើងបានលើកឡើងរួចមកហើយ។

ខ្ញុំសូមបន្ថយល្បឿនបន្តិចព្រោះថាខ្ញុំនិយាយលឿនពេកហើយមើលទៅ។ ពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធី នៅពេលដែលយើងឡើងអន្តរាគមន៍នោះ យើងបានលើកឡើងថា ខ្ញុំនឹក ខ្ញុំនិយាយច្បាស់ថាយើងមិនធ្វើប្តឹងឧទ្ធរណ៍ទៅលើដីកាបំបែកនេះទេ។ ហើយលើកទី១ក៏មិនបានប្តឹងឧទ្ធរណ៍ លើកទី២ក៏មិនបានប្តឹងឧទ្ធរណ៍ដែរ។ ដោយសារតែយើងមិនបានប្តឹង ដោយសារតែមូលហេតុទាំងអស់ហ្នឹងហើយ។ នេះជាចំណុចទី១។

[១២:០១:៥៣]

ចំណុចទី២ មិនមែនជាចំណុចថ្មីទេ មិនមែនជាលើកទី១ដែលយើងនិយាយទេ។ យើងបាន

និយាយតាំងពីដើមសវនាការមកម្ល៉េះ ចាប់តាំងពីពេលដែលយើងទទួលបានឱកាសនិយាយទាំងនៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំរៀងចំសវនាការ ទាំងក្របខ័ណ្ឌនៃកិច្ចប្រជុំពាក់ព័ន្ធទៅនឹងសារណាបញ្ចប់។ ខ្ញុំតែងតែនិយាយរហូត។

ហើយដើមបណ្តឹងរដ្ឋប្បវេណីថា និយាយថាដោយយើងតវ៉ាថាមានឯកសារច្រើន។ ដោយសារតែមានឯកសារច្រើនហ្នឹងហើយដែលថា ដូចនៅក្នុងតុលាការផ្សេងទៀតនេះ យើងទាមទារឲ្យមានឱកាសក្នុងប្រៀបធៀបភស្តុតាងទាំងអស់ហ្នឹង ទាំងភស្តុតាងសក្ខីកម្ម ទាំងឯកសារភស្តុតាងទាំងអស់ គឺថាយើងចង់ឲ្យធ្វើម៉េចអាចលើកឡើងឲ្យបានជាក់លាក់ អាចឲ្យយើងបានពិភាក្សាទៅលើឯកសារទាំងអស់នោះ។ ហើយការដែលឲ្យយើងសរសេរសារណាបញ្ចប់ត្រឹមតែ១០០ទំព័រនោះ គឺថាមិនគ្រប់គ្រាន់ទេ វាមិនអាចឲ្យយើងធ្វើការពិភាក្សាជជែកវែកញែកឲ្យបានពេញលេញទៅលើអ្វីដែលយើងអាចចង់និយាយនោះទេ នៅពេលដែលចប់សវនាការនោះ។ នេះជាមិនមែនជាលើកទី១ទេ ដែលយើងខ្ញុំបានលើកឡើងនោះ។

[១២:០២:០៦]

ដូច្នេះជាថ្មីម្តងទៀត គឺថាអ្វីដែលយើងបានលើកឡើងនៅក្នុងអគ្គបទភ្នំពេញប៉ុស្តិ៍នោះ គឺថាវាជាអ្វីដែលយើងបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងក្នុងឯកសារ E288/4 គឺថា ហើយនៅពេលដែលយើងពិនិត្យមើលប្រតិចារឹកសវនាការផ្សេងៗនោះ គឺថាយើងឃើញហើយនូវការកត់សម្គាល់របស់យើងទាំងអស់ហ្នឹង។ អ៊ីចឹងគឺថានៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទី១ ក៏ខ្ញុំបាននិយាយ កិច្ចប្រជុំសវនាការ -- រៀបចំសវនាការផ្សេងទៀត ក៏ខ្ញុំនិយាយដែរ។ ហើយប្រសិនបើលោក អស់លោកលើកឡើងថាមិនដែលឮគោលជំហរនេះរបស់មេធាវីការពារក្តី គឺមិនត្រឹមត្រូវទេ។ ឯកសារដែលថាឲ្យយើង១០០ទំព័រហ្នឹង យើងបាននិយាយច្រើនដងហើយ ហើយយើងឃើញថាព្រះរាជអាជ្ញាទទួលបាន២០០ទំព័រ ហើយនៅពេលនោះគឺថាគាត់មានជនជាប់ចោទបីនាក់ ហើយដល់ពេលតែជនជាប់ចោទសល់តែពីរនាក់ក៏គាត់នៅតែ២០០ទំព័រដដែល។ អៀង សារី គាត់លែងនៅក្នុងសវនាការនេះហើយ លែងនៅក្នុងការជំនុំជម្រះសេចក្តីហ្នឹងហើយ គាត់នៅតែទទួលបាន២០០ទំព័រដដែល។

[១២:០៤:០៩]

ដូច្នេះ ខ្ញុំបានលើកឡើងហើយថាគាត់ -- សហព្រះរាជអាជ្ញាគឺថាគាត់មានប្រៀបជាងយើង។ ដូច្នេះនៅពេលដែលយើងនិយាយថា មិនអាចទទួលយកបាន ដូចថាខ្ញុំនិយាយថាមិនអាចទទួលយកបាន

ចំពោះឯកសារ១០០ទំព័រ គឺមិនមែនជារឿងថ្មីទេ យើងបាននិយាយច្រើនលើកច្រើនសាមកហើយនៅក្នុងសំណើរបស់យើង ហើយក៏យើងលើកយកមកនិយាយនៅក្នុងនេះ។

ដូច្នេះសំណើរបស់យើងគឺបានចុះផ្សាយជាសាធារណៈហើយអំពីគោលជំហររបស់យើង។ ដូច្នេះយើងទាំងអស់គ្នាដឹងហើយ ទាំងអង្គជំនុំជម្រះ ទាំងដើមបណ្តឹងរដ្ឋប្បវេណី ទាំងសហព្រះរាជអាជ្ញា ដឹងអំពីគោលជំហររបស់យើងក្នុងឋានៈយើងជាមេធាវីការពារក្តី។ យើងមិនមែនធ្វើដើម្បីបំពេញចិត្តអ្នកណាទាំងអស់នោះទេ។ យើងត្រូវតែបង្ហាញអំពីគោលជំហររបស់កូនក្តីរបស់យើង និងបង្ហាញអំពីគោលជំហររបស់មេធាវីយើង។ អ្នកណាពេញចិត្ត មិនពេញចិត្ត គឺជារឿងរបស់គេ ប៉ុន្តែនេះជាការជំនុំជម្រះក្តី។ យើងត្រូវតែធ្វើការវិភាគទៅលើឯកសារភស្តុតាង ហើយវាមិនដូចគ្នា យើងវិភាគផ្សេងខុសពីការិយាល័យសហព្រះរាជអាជ្ញា ខុសពីដើមបណ្តឹងរដ្ឋប្បវេណី។ ម្នាក់ៗមានទស្សនៈផ្សេងគ្នាក្នុងការវិភាគ។ នេះហើយជាការជំនុំជម្រះក្តី។ យើងត្រូវតែប្រឈមមុខនឹងទស្សនៈផ្សេងៗគ្នា យើងមិនអាចមានទស្សនៈដូចគ្នាទេ។ ហើយយើងអ្វីដែលយើងលើកឡើងនោះគឺថា -- អ្វីដែលយើងលើកឡើងទស្សនៈនោះគឺថា យើងលើកឡើងនៅក្នុសំណើទៅហើយ ហើយលោក ខៀវ សំផន ក៏គាត់បានលើកឡើងដែរ នៅពេលដែលគាត់និយាយ។ ហើយជាពិសេសតាមរយៈលោកមេធាវី វ៉េកគែន, ខ្ញុំ ឬក៏ គង់ សំអុន នោះ។ គឺយើងបាននិយាយរួចអស់មកហើយនៅក្នុងសវនាការ នៅពេលដែលគេមិនបិទ ផ្តាច់មីក្រូឲ្យយើងនិយាយនោះគឺយើងបាននិយាយ។ ហើយយើងក៏និយាយតែដដែលៗ។ ឥឡូវនេះក៏យើងនិយាយឡើងវិញម្តងទៀតនៅក្នុងអត្ថបទកាសែត និយាយជាសាធារណៈ ដូចដែលយើងបានដាក់នៅក្នុងឯកសារ E288/4 ដែលយើងនិយាយជាសាធារណៈរួចហើយ។

[១២:០៦:០៦]

ដូច្នេះ អ្វីៗគឺគ្មានថ្មីទេ ដដែលទាំងអស់ ហើយប្រសិនបើថាដាក់ទណ្ឌកម្មដោយសារយើងផ្តល់នូវទស្សនៈរបស់យើងដោយសារយើងបញ្ចេញមតិយោបល់របស់យើងក្នុងឋានៈជាមេធាវីការពារក្តីនោះ ខ្ញុំសូមឲ្យយើងពិនិត្យទៅមើល ទៅលើគោលការណ៍មូលដ្ឋានដែលបានអនុម័តកាលពីសន្និសីទលើកទី៨ របស់អង្គការសហប្រជាជាតិនោះ គឺជាគោលការណ៍មូលដ្ឋានរបស់សហប្រជាជាតិពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស។ គឺនិយាយអំពីតួនាទីរបស់គណៈមេធាវី នៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិនោះ។ គឺកថាខណ្ឌ២៣នេះ និយាយអំពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ គឺថាមេធាវី ក៏ដូចជាប្រជាជនផ្សេងទៀតដែរ គាត់មានសិទ្ធិក្នុងការនិយាយស្តី។ ដូច្នេះ យើងប្រើប្រាស់សេរីភាពរបស់យើងនេះ គ្រប់ តាម

គ្រប់វិធីទាំងអស់នេះ តាមរយៈការនិយាយនៅចំពោះមុខមីក្រូ តាមរយៈការនិយាយតាមសារព័ត៌មាន តាមរយៈសំណើ។ ដូច្នេះ វាអត់មានអីជារឿងថ្មីទេ។ អ្វីដែលយើងទៅដល់សារព័ត៌មាននេះ យើងបាននិយាយជូនអង្គជំនុំជម្រះអស់ហើយ ហើយអង្គជំនុំជម្រះក៏បានដឹងដែរ ហើយយើងក៏សរសេរជាសំណើដែរ។ ដូច្នេះ ខ្ញុំមិនដឹងថាហេតុអីក៏យើងនាំគ្នាចោទថាខ្ញុំនិយាយរឿងថ្មីនោះទេ។ ហើយគាត់ សហព្រះរាជអាជ្ញានោះ គាត់ចង់ឲ្យឃើញថាហេតុការណ៍នោះ ជាហេតុការណ៍ពិសេសមួយជាក់លាក់។ គឺវាមិនត្រឹមត្រូវទេ។ យើងបានពន្យល់អំពីគោលជំហររបស់លោក ខៀវ សំផន ហើយ យើងបាននិយាយអំពីយុត្តិសាស្ត្ររួចមកហើយ។

[១២:០៧:៣៨]

ដូច្នេះ អ្នកណាចង់ថាម៉េចថាទៅ។ យើងមិនខ្វល់ទេ ក៏ប៉ុន្តែក្នុងឋានៈជាមេធាវីការពារក្តី យើងមានសិទ្ធិក្នុងការនិយាយថា ហេតុអ្វីបានកូនក្តីរបស់យើងបង្ហាញជំហរបែបណា? យើងអាចនិយាយតាមសវនាការ យើងអាចនិយាយសំណើ ឬក៏តាមសារព័ត៌មាន មិនមានការប្រមាថមើលងាយអីទេ។ អ្វីដែលយើងបានបរិហារនៅក្នុងកាសែតនោះ គឺថាយើងធ្លាប់និយាយនៅក្នុងអង្គជំនុំជម្រះរួចហើយ។ ប្រសិនបើការនិយាយហ្នឹងនាំឲ្យមានការដាក់ទណ្ឌកម្មនោះ គឺថាខ្ញុំគិតថាមេធាវីការពារក្តី គឺថាមិនមានសិទ្ធិក្នុងការនិយាយស្តីហើយនៅក្នុងការធ្វើបែបនេះនោះ។ យើងមានជំហររបស់មេធាវីការពារក្តីហើយ ជំហរនេះមិនមែនជាជំហរថ្មីទេ។ ហើយជំហរនេះគឺថាផ្អែកទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

ដូច្នេះ ខ្ញុំសូមឲ្យភាគីទាំងអស់ពិនិត្យមើលនូវអន្តរាគមន៍លម្អិតរបស់លោក អាកទ័រ វែកគែន ដែលគាត់បានពន្យល់នៅក្នុងសវនាការថា ហេតុអីបានជាក្រុមយើងមិនចង់ចូលរួមនៅក្នុងសវនាការស្តីពីឯកសារ។

[១២:០៨:៣៩]

ដូច្នេះ ជាថ្មីម្តងទៀត អ្វីដែលយើងខ្ញុំលើកឡើងនៅក្នុងសារព័ត៌មានគឺមិនមានអីថ្មីទេ។ គឺជារឿងដដែលៗ សវនាការនេះជាសវនាការសាធារណៈ យើងបានដឹងទាំងអស់គ្នាហើយ ហើយយើងក៏អាចមើលប្រតិចារឹកសវនាការដែរ ពេលដែលយើងមើលទៅ គឺយើងឃើញហើយ ពីគោលជំហររបស់លោក ខៀវ សំផន ហើយនិងមានទទឹ្ធករណ៍ដែលបង្ហាញគាំទ្រទៅដល់ការបង្ហាញជំហរបែបនេះ។

ដូច្នេះ គ្មានអ្វីដែលលើកឡើងថាជារឿងថ្មីទេនៅក្នុងអត្ថបទនោះ នោះ។ គ្រាន់តែយើងយកមកចុះផ្សាយនៅក្នុងសារព័ត៌មាន គឺថាយកអ្វីដែលមានដដែលហ្នឹងយកមកចុះផ្សាយ។ ដូច្នេះ អ្វីៗទាំងអស់

យើងធ្វើឡើងជាសាធារណៈ គោលជំហរយើងបង្ហាញជាសាធារណៈ សវនាការធ្វើឡើងជាសាធារណៈ ហើយក្នុងនាមជាមេធាវីការពារក្ដីលោក ខៀវ សំផន យើងមានសិទ្ធិក្នុងការពន្យល់ថា ហេតុអ្វីបានជាលោក ខៀវ សំផន ប្រកាន់ជំហរបែបណានោះ។

ដូច្នេះ បើយើងគិតថាការប្រកាន់ជំហរបែបនេះមិនត្រឹមត្រូវ ខុសនោះ គឺថាវាជាការរឹតត្បិតលើសិទ្ធិរបស់លោក ខៀវ សំផន ហើយនៅក្នុងការដែលយើងនាំគ្នាចោទប្រកាន់ថាគាត់ប្រកាន់ជំហរមិនត្រឹមត្រូវនោះ។ ហើយគាត់ គាត់បានពន្យល់អស់ហើយ ថាហេតុអ្វីបានជាគាត់មានប្រតិកម្មតបទៅនឹងអ្វីដែលបានកើតឡើង ហើយគាត់រក្សាសិទ្ធិគាត់ក្នុងការមិនឆ្លើយតបនោះ។

[១២:០៩:៥៤]

ដូច្នេះ យើង -- គេនាំគ្នាចោទយើងជាមេធាវីដែលធ្វើមិនត្រូវ ជាមេធាវីដែលមិនធ្វើតាមក្រមសីលធម៌នោះ។ យើងបានពន្យល់អស់ហើយ តាំងពីដើមមកហើយថា ហេតុអីក៏មានការកម្រិតត្បិតទំព័រឲ្យយើងសរសេរឯកសារត្រឹមតែ១០០ទំព័រអីហ្នឹង។ យើងបានពន្យល់អស់ទៅហើយ ថាហេតុអីបានជាយើងយល់ថា ការដែលកាត់ផ្ដាច់កុំឲ្យខ្ញុំនិយាយហ្នឹង គឺជាការពេញចិត្ត ពីការចង់បានរបស់អង្គជំនុំជម្រះនោះ។ ខ្ញុំនិយាយហើយនេះជាការកាត់ក្ដី យើងត្រូវតែប្រឈមមុខគ្នាទៅនឹងទស្សនៈផ្សេងៗ ហើយអង្គជំនុំជម្រះជាអ្នកចេញសេចក្ដីសម្រេច យើងអត់មានជម្រើសអីផ្សេងទៀត។ យើងពិនិត្យមើលទៅសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទៅតាមព័ត៌មានដែលយើងអាចទទួលបាននៅក្នុងក្របខ័ណ្ឌនៃសវនាការ។

ដូច្នេះខ្ញុំសូមលើកឡើងម្ដងទៀតថា អ្វីដែលខ្ញុំលើកឡើងនៅក្នុងអត្ថបទកាសែតនោះ គឺមិនមែនជារឿងអ្វីថ្មីទេ។ ហើយប្រសិនបើមានការដាក់ទណ្ឌកម្មរបស់ខ្ញុំនោះ គឺថាខ្ញុំនិយាយថាជាការសោកស្ដាយណាស់ដែលគ្រាន់តែយើងបង្ហាញអំពីសិទ្ធិរបស់យើងក្នុងការបញ្ចេញមតិយោបល់ ហើយគេដាក់ទណ្ឌកម្មយើងនោះ។ ដូច្នេះខ្ញុំសូមលើកឡើងម្ដងទៀត ថាជាការសោកស្ដាយបំផុត។

[១២:១១:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបានកត់សម្គាល់ឃើញថា ពេលវេលាហួសហើយ ប៉ុន្តែខ្ញុំសូមលើកដោយខ្លីទាក់ទងទៅនឹងការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ក៏ដូចជាការមេធាវីដើម

បណ្ដឹង តំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

អ្វីដែលខ្ញុំអាចពិនិត្យ ឆ្លើយតបជារួម ឃើញថាការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាហាក់ដូចជាប្រញាប់ប្រញាល់ពេក។ ហើយការដាក់នូវសំណើមួយដែលសុំឲ្យតុលាការធ្វើការដាក់វិន័យចំពោះការបំពានវិជ្ជាជីវៈណាមួយរបស់មេធាវីនេះ គឺពុំបានធ្វើឲ្យបានស្របតាមបច្ចេកទេស ឬបទដ្ឋានដែលអាចទទួលយកបានអំពីបែបបទ ដែលត្រូវដាក់ពាក្យនោះទេ។

តុលាការពិនិត្យទៅលើបញ្ហាដែលកើត ដែលបានលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាវាជាបញ្ហាមួយ ដូចមេធាវីអន្តរជាតិលោកស្រី អង់តា ហ្គីសសេ បានលើកហើយថា វាពុំមានអ្វីថ្មីនៅក្នុងសារព័ត៌មាននោះឡើយ។ ហើយអ្វីដែលខ្ញុំនិយាយថាវាប្រញាប់ពេកនោះ គឺតំណាងសហព្រះរាជអាជ្ញាមិនបានសិក្សាលម្អិតទៅលើអត្ថបទនោះ ថាតើចំណុចណាខ្លះដែលជាចំណុចធ្វើឲ្យប៉ះពាល់ទៅដល់វិជ្ជាជីវៈ ដែលមេធាវីការពារក្ដីលោក ខៀវ សំផន បានលើកឡើងនោះទេ។

[១២:១២:៥៥]

ការគូសបញ្ជាក់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិទៅលើការដែលថា ក្រុមមេធាវីរបស់លោក ខៀវ សំផន ជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ គឺជារឿងសន្និដ្ឋានមិនត្រឹមត្រូវហើយដែលជាការទាញដើម្បីធ្វើឲ្យមតិជាតិ មតិសាធារណៈ និងមតិអន្តរជាតិយល់ច្រឡំទៅលើអត្ថបទដែលជាការបញ្ចេញមតិរបស់ក្រុមមេធាវីរបស់លោក ខៀវ សំផន។

ហើយចំណុចមួយទៀត ដែលខ្ញុំសូមឆ្លើយជារួមដែរអំពីការលើកឡើងរបស់មេធាវីតំណាងដើមបណ្ដឹង -- មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទាំងមេធាវីអន្តរជាតិ និងមេធាវីជាតិ ដែលលើកអំពីការសោកស្ដាយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អំពីការមិនឆ្លើយតបរបស់លោក ខៀវ សំផន។ បញ្ហានេះតុលាការអាចជ្រាបហើយថា ទីនេះជាតុលាការដែលត្រូវកាត់ទោស ឬក៏បើកការជំនុំជម្រះលោក ខៀវ សំផន ដែលជនជាប់ចោទនៅទីនេះ។ ការសម្រេចមិនឆ្លើយរបស់លោក ខៀវ សំផន ចំពោះសំណួរដែលតាំងឡើងដោយភាគី ក៏ដូចជាអង្គជំនុំជម្រះ វាជាសិទ្ធិរបស់លោក ខៀវ សំផន។

[១២:១៤:២៧]

ការពិនិត្យមើលទៅលើការប្រើប្រាស់ និងជំនឿរបស់លោក ខៀវ សំផន ចំពោះតុលាការវាជាការសម្រេចផ្ទាល់ខ្លួនរបស់លោក ខៀវ សំផន ដែលលោកបានមើលឃើញអំពីបញ្ហាដែលកើតឡើងនៅក្នុងនីតិវិធីនៃតុលាការនេះ។ អ៊ីចឹងខ្ញុំសូមរំឭកថា ផលប៉ះពាល់របស់លោក ខៀវ សំផន ដែលអាច

កើតឡើងពីបញ្ហាដែលកើតមានចេញពីតុលាការនេះ វាធ្ងន់ធ្ងរសម្រាប់លោក ខៀវ សំផន ដែលគាត់នឹងត្រូវទទួលទោស បើសិនជាតុលាការនេះមិនបានប្រើប្រាស់នៅនីតិវិធីត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិក្នុងការស្វែងរកយុត្តិធម៌។ ដូច្នេះហើយទីនេះមិនមែនជាកន្លែងសម្រាប់សាធារណជនស្តាប់នូវការសម្តែង ឬក៏មិនមែនជាសាលាសម្រាប់ឲ្យអ្នកស្រាវជ្រាវសរសេរប្រវត្តិសាស្ត្រនោះទេ។ វាជាការកាត់ទោស ដូច្នេះហើយការពិនិត្យទៅលើភាពហ្មត់ចត់នៃលទ្ធផល ក៏ដូចជាការទុកចិត្ត ការមានជំនឿទៅលើប្រព័ន្ធតុលាការ វាជាការសម្រេចរបស់លោក ខៀវ សំផន ថាតើលោកអាចឆ្លើយ និងសហការជាមួយតុលាការក្នុងកម្រិតណានោះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១៦:៥២]

**ប្រធានអង្គជំនុំ៖**

បាទ ហើយកិច្ចដំណើរការសម្រាប់ថ្ងៃនេះ គឺការស្តាប់សក្ខីកម្មសាក្សីហ្នឹងបានចប់ហើយ ហើយដោយអង្គជំនុំជម្រះមិនទាន់បានកំណត់អំពីកាលវិភាគធ្វើសវនាការបន្តនៅឡើយ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការពីពេលនេះតទៅរហូតដល់ថ្ងៃអង្គារ ទី២៣ ខែកក្កដា ឆ្នាំ២០១៣។

អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីនៃរឿងក្តី ហើយមន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាបថា អង្គជំនុំជម្រះនឹងធ្វើសវនាការប្រកាសជម្រាបជូនដំណឹងអំពីកាលវិភាគបន្តធ្វើសវនាការនាពេលខាងមុខរបស់ខ្លួនដល់ភាគី និងសាធារណជន និងស្តាប់នូវមតិយោបល់តំណាងសហព្រះរាជអាជ្ញាដែលនឹងលើកឡើងអំពីបញ្ហាចាំបាច់នានាដែលនៅសេសសល់ និងអាចស្តាប់នូវមតិយោបល់របស់ភាគីដទៃទៀតនៃរឿងក្តីនៅសាលសវនាការនេះនៅថ្ងៃអង្គារ ទី២៣ ខែកក្កដា ឆ្នាំ២០១៣ ហើយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សូមភាគីនៃរឿងក្តីជ្រាប និងអញ្ជើញចូលរួម ហើយមន្ត្រីបុគ្គលិក ហើយមន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការ និងសាធារណជនជ្រាប។

[១២:១៨:០៤]

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃអង្គារ ទី២៣ ខែកក្កដា ឆ្នាំ២០១៣ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ

ដែលមានរៀបចំនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១២:១៨ នាទី)*